# ពោធិបក្ខិយកថា

ព្រះឧបាលិវង្ស ម៉ុខ សែស ចៅអធិការវត្តមហាមន្ត្រី

ក្រុងភ្នំពេញ

បានរៀបរៀង

សង្ក្រិសម្ពាយ

បញ្ញិត · កុត · កុសល (សម្បុបញ្ញត្តិ)

គណៈវដ្តមន្ត្រី នឹង សម្តេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

បោះពុម្ពលើកទី ១

បោះនៅរោងពុម្ពអាល្បែរពរតែ

ភ្នំពេញ

ព.ស.២៤៩២ គ.ស. ១៩៤៩

# ពោធិបក្ខិយកថា

ព្រះឧបាលិវង្ស ម៉ឹង សែស ចៅអធិការវត្តមហាមន្ត្រី

ក្រុងភ្នំពេញ

បានរៀបរៀង

គណៈវត្តមន្ត្រី នឹង សម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ


បោះពុម្ពលើកទី ១

បោះនៅរោងពុម្ពអាល្បែរពរតែ

ភ្នំពេញ

ព.ស.២៤៩២ គ.ស. ១៩៤៩

Adam Lamane

# ឧ ប ត្តិ ហេ តុ

សៀវភៅពោធិបក្ខិយកថាដែលព្រះតេជៈព្រះគុណ អស់លោកពុទ្ធបរិស័ទ កំពុងកាន់អាននេះកើតឡើងដោយ ខ្ញុំព្រះករុណា ខ្ញុំបាទយល់ឃើញថាមានប្រយោជន៍ដល់ពុទ្ធ- សាសនិកជនទូទៅដែលចង់ចេះដឹងឲ្យបានជ្រៅជ្រះក្នុង ព្រះពុទ្ធសាសនាខ្មែរយើង ។

ខ្ញុំព្រះករុណា ខ្ញុំបាទ អ៊ុត ផាត់ នាង ផង់ ស៊ាម ជាភរិយា បានចំណាយប្រាក់ទិញក្រដាស់នឹងសម្ភារៈផ្សេងៗ និមន្តព្រះភិក្ខុធម្មសារោ ព្រហ្ម ជួប ជួយបោះពុម្ពតាមច្បាប់ដើម នឹងចងក្រងជាសៀវភៅ ១០០ក្បាល ជាធម្មទាន ។

ខ្ញុំព្រះករុណាខ្ញុំបាទសូមឧទ្ទិសបុណ្យកុសលនេះជូនដល់បុព្វបុរសទាំងអស់គឺៈ មាតា បិតា គ្រូឧបជ្ឈាយាចារ្យ នឹង ញាតិកាទាំង ៧ សន្តាន ឲ្យបានសម្រេចសម្បត្តិ៣ប្រការ គឺៈ សម្បត្តិមនុស្ស សម្បត្តិឋានសួរនឹង ឋានព្រះនិព្វាន- នូវអនាគតកាលឯមុខនោះហោង ។

ថ្ងៃទី ៣១ ខែ សីហា គ.ស.១៩៩៣

អ៊ុត ផាត់ នាង ផង់ ស៊ាម

ព្រះពុទ្ធតាមច្បាប់ដើម

លើកទី ១

នៅវត្ត បាលិលេយ្យ ចំនួន ១០០ ច្បាប់

**PALELAI BUDDHIST TEMPLE, INC.**
240 Greenwich Street
Philadelphia, PA 19147
Tel: (215) 339-5830-40

# អារម្ភកថា

ហេតុដែលនាំឲ្យកើតសៀវភៅពោធិបក្ខិយកថានេះឡើង គឺកើតឡើងដោយលោកមេឃុំ កែ-ម៉ក់ បានអារាធនាខ្ញុំឲ្យរៀបរៀង ខ្ញុំនៅគង់វត្តមហាមន្ត្រី ឃុំលេខ១៨ ក្រុងភ្នំពេញ មេឃុំ កែ-ម៉ក់នៅខាងជើងជិតវត្តមហាមន្ត្រី មេឃុំនេះបានមើលសៀវភៅ ព្រហ្មវិហារកថារបស់ខ្ញុំ ឃើញសេចក្ដីថា ពោធិបក្ខិយធម៌ ៣៧ តែមិនអាចប្រាប់ថា ៣៧ តើអ្វីខ្លះ ចង់ប្រាប់ឲ្យច្បាស់លាស់យកជាផ្លូវប្រតិបត្តិតរៀងខ្លួនទៅ ទើបអារាធនាខ្ញុំឲ្យរៀបចំធ្វើឡើង ខ្ញុំក៏មិនសូវនឹងទទួលភារៈនេះទេ ព្រោះមិនសូវសប្បាយខ្លួន ប៉ុន្តែបានជាទទួលការនេះព្រោះខ្ញុំមានបំណងនឹងធ្វើពោធិ-បក្ខិយធម៌នេះជាយូរណាស់ហើយ ព្រោះកាលដែលខ្ញុំនៅធ្វើសាស្ត្រាចារ្យបង្រៀនបាលីក្នុងវត្តបូព៌កោះសំពេច កំពង់ចាម ខ្ញុំបានធ្វើពោធិបក្ខិយ-ធម្មៈសៀវភៅ បោះពុម្ពហើយចែកចាយដល់ជនានុជនបានរៀនទន្ទេញចេះចាំច្រើនគ្នា បានចែកផ្សាយទៅច្រើនស្រុក មកដល់សម័យខាងក្រោយខ្ញុំមានបំណងនឹងធ្វើទៀត ដូនលើមេឃុំ កែ-ម៉ក់អារាធនាខ្ញុំក៏ទទួលធ្វើដោយសោមនស្ស ។

ឯមេឃុំ កែ-ម៉ក់នេះកើតថ្ងៃចន្ទ ១១រោច ឆ្នាំជូត ឆស័ក ព.ស. ២៤២៩ កើតនៅភូមិស្រុលឃុំស្មោងស្រុកព្រៃនរ ខេត្តតាកែវ បិតាឈ្មោះកែ ចិត្តកញ្ញាយោធាធិបតី ចៅហ្វាយខេត្តបន្ទាយមាស មាតាឈ្មោះលោកស្រីទេព កាលជាខាងក្រោយបាននៅនៅគង់ភូមិតានីខេត្តបន្ទាយមាស ទើបបិតាបានធ្វើជាចៅហ្វាយខេត្ត មេឃុំ កែ-ម៉ក់

កាលដែលមានអាយុ១២ឆ្នាំ បានចូលបួសជាសាមណេរក្នុងវត្តប្រាសាទ (តាខី) បាន១វស្សាក៏ប.ឧបជ្ឈាយ៍ ទៅនៅរៀនបរិយត្តិក្នុងវត្តពន្លឺ ក្នុងសំណាក់លោកគ្រូចៅអធិការព្រះនាម (គិម) និងលោកគ្រូព្រះអាចារ្យពេជ្រផាឧបាសក រៀនបាន៣វស្សាក៏បាកសិក្ខាអំពីភេទជាសាមណេរមកជាភេទគ្រហស្ថវិញ ។

លុះដល់អាយុ២០ឆ្នាំចូលបួសជាភិក្ខុក្នុងវត្តប្រាសាទដដែល លោកគ្រូឧបជ្ឈាយ៍ព្រះនាមពៅ លោកគ្រូសូត្រស្តាំព្រះនាមជេត លោកគ្រូសូត្រឆ្វេងព្រះនាមកែវ បួសបាន១វស្សាក៏បាកសិក្ខាមកជាគ្រហស្ថវិញ មាតាបិតាក៏រៀបការអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកស្រី អ៊ុក ង៉ែត ជាគូស្វាមីភរិយារហូតមកដល់សព្វថ្ងៃនេះ ។

លុះដល់អាយុ២៤ឆ្នាំ លោកឧកញ៉ាខាវចៅហ្វាយខន្ធយាមៈស រើសឱ្យធ្វើភាគទុរ្យីយោធរសុិជនក់កតគ សម័យជាខាន់ក្រោយមកទៀត លោកឧកញ៉ាពៅ ចៅហ្វាយបន្ទាយមាស ។ តាំងឱ្យធ្វើជាបំរើខែត្រគន្ធតាមខែត្របន្ទាយមាសបាន១ឆ្នាំ ។ ក្រោយទៀតបានធ្វើជាចំរើខែត្រគន្ធស្បូវ ជាជំហុមធំបតី លុះដល់អាយុ២៨ឆ្នាំ បានធ្វើជាមេឃុំ ១ ត្រពាំងរុនតាខី ក្នុងរវាងអាយុ ២៨ ឆ្នាំនោះ ក៏ហាក់ដូចជាទេវតាមកតម្រូវលឱ្យឃើញសុបិននិមិត្តជាអស្ចារ្យ នាំឱ្យត្រាស់បាប ខាងបាប ប្រាញបុណ្យ បានចូលសមាទានសីលជាមួយនឹងអ្នកស្រី អ៊ុក-ង៉ែត ជាភរិយា បានបរិច្ចាគធនធាននានាខាងក្នុងព្រះពុទ្ធសាសនាជាច្រើន ។

១.— បានសាងក្រាំងព្រះបាតិមោក្ខអក្សរទឹកមាស ព្រមទាំងក្រែ ព្រះបាតិមោក្ខដាក់ក្រែបិទមាសជើងទៀនក្តុក ។

២.— បានជាវគម្ពីរព្រះត្រៃបិដកអក្សរសៀម អំពីស្រុកសៀម ថ្លៃ ៧០០ រៀល ព្រមទាំងទូដាក់គម្ពីរនោះផង បានតំកល់ទុកក្នុងវត្ត ប្រាសាទសព្វថ្ងៃនេះ ។

៣.— បានសាងព្រះស្តូបពីមាស ១ សំរាប់ដាក់ព្រះសារីរិកធាតុ ។

៤.— កាលដែលកជការព្រះករុណា ព្រមទាំងកជការបាក់នំសែស បានបង្កើតឲ្យមានបោះពុម្ពព្រះត្រៃបិដកជាអក្សរខ្មែរឡើង បានបបួលឧ-បាសកឧបាសិកាឲ្យច្រើនមកជួយរកជការ ក្នុងការកសាងព្រះត្រៃបិដក បាន ២ លើក ចំនួនទឹកប្រាក់ ២០០០ រៀល តំកល់ទុកក្នុងព្រះរាជ-បណ្ណាល័យ ។

៥.— បានបបួលឧបាសកឧបាសិកាធ្វើសង្ឃាដី ២ ជាន់បានចំនួន ១៥០ សង្ឃាដី ប្រគេនព្រះភិក្ខុសង្ឃក្នុងស្រុកបន្ទាយមាសតាមចំនួន សង្ឃាដី ។

៦.— បានបបួលឧបាសកឧបាសិកាធ្វើបុណ្យផ្កាសមាគមបច្ច័យជួយ ក្នុងការកសាងព្រះវិហារវត្តពោលើ ស្រុកកណ្តាលស្ទឹង បាន ២ ដង ចំនួនទឹកប្រាក់ជាង ២០០០ រៀល ។

៧.— បានបបួលឧបាសកឧបាសិកា ធ្វើព្រះវិហារវត្តត្រពាំងខ្វា ឃុំគគីរ ស្រុកបន្ទាយមាស ទិញឥដ្ឋឈើ ក្រាលព្រះវិហារវត្តពន្ធី ឃុំស្រុកជាមួយគ្នា ។

មេឃុំ កែ-ម៉ក់ មានឧបការៈច្រើនក្នុងព្រះពុទ្ធសាសនាយ៉ាងនេះ ដោយហេតុមានប្រាថ្នាជាពុទ្ធភូមិ សូមឲ្យបានត្រាស់ជាព្រះពុទ្ធ ១ ព្រះអង្គក្នុងអនាគត ។

ចំណែកផ្លូវរាជការអាណាចក្រក៏មេឃុំ កែ-ម៉ក់ មានឧបការៈច្រើនដែរ បានធ្វើជាកុងស៊ីយេនិងមេឃុំជាយូរឆ្នាំហើយ គ្មានសៅហ្មងក្នុងផ្លូវរាជការទេ រាជការបានចំពាក់គ្រឿងឥស្សរិយយសមេដៃប្រាក់ ១ មាស ១ ទុកជាកិត្តិយសក្នុងដែនកម្ពុជា ។

វេលាដែលចាស់ជរាហើយ បានលាឈប់ធ្វើរាជការ ហើយបានចូលមកនៅក្នុងក្រុងភ្នំពេញ បានជួបនឹងខ្ញុំដោយហេតុនៅជិតគ្នា មានសទ្ធាចង់ធ្វើធម្មទានដំឡើងវិការមួយលើកទៀត បានជាអារាធនាខ្ញុំឲ្យរៀបចំធ្វើពោធិបក្ខិយធម៌នេះឡើង ខ្ញុំក៏បានទទួលធ្វើដោយសោមនស្ស ដើម្បីជូនសទ្ធាមេឃុំ កែ-ម៉ក់ ផង ដើម្បីជាផ្លូវកសាងកុសលរបស់ខ្ញុំផង ។

ថ្ងៃ ១ ៗ ១២ ឆ្នាំរកាសប្តស័ក ព.ស. ២៤៨៨

ព្រះឧបាលិវង្ស ម៉ុង-សែស

# ពោធិបក្ខិយកថា

វត្ថូនិ សិរសា តីណិ　　សក្កច្ចមភិវន្ទិយ
ពោធិបក្ខិយធម្មាយេ　　សម្ពុទ្ធេន សុទេសិតា
ធម្មកាមានមត្ថាយ　　តេ ភាសិស្សំ សមាសតោ
អភិវាទានុភាវេន　　សុវត្ថិ ហោតុ នោ សទា ។

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំដោយគោរព បំពោះវត្ថុទាំង ៣ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសិរាវយវៈគឺត្បូង ហើយនឹងពោលអធិប្បាយដោយសង្ខេប នូវពោធិបក្ខិយធម៌ទាំងឡាយ ដែលព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងហើយដោយល្អ ដើម្បីជាប្រយោជន៍ដល់ពួកជនដែលរាប់អានស្រឡាញ់ធម៌ពិត ៗ ដោយអានុភាពនៃការថ្វាយបង្គំរបស់ខ្ញុំ សូមសិរីសួស្តីជ័យមង្គល ប្រូលមានដល់យើងទាំងឡាយសព្វ ៗ កាល ។

នឹងសំដែងនូវពោធិបក្ខិយធម៌ ពាក្យថាពោធិបក្ខិយធម៌ប្រែថាធម៌កើតមានក្នុងបំណែក នៃអរិយមគ្គជាគ្រឿងត្រាស់ដឹងនូវចតុរារិយសច្ច ព្រោះព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើមតែងបានត្រាស់ដឹងអរិយសច្ច បានសំរេចមគ្គផល

និព្វាន គឺបានដោយពោធិបក្ខិយធម៌នេះឯង ព្រោះហេតុនោះ ពួកជនដែលមានប្រាជ្ញាឃើញទុក្ខភ័យសេចក្តីអន្តរាយផ្សេង ៗ ក្នុងសង្សារវដ្ត គួរសិក្សាគួរចំរើននូវពោធិបក្ខិយធម៌នេះ ដើម្បីឲ្យបានសំរេចព្រះនិព្វានជាស្ថានបរមសុខ ឥតមានជាតិជរាព្យាធិមរណ និងទោសទុក្ខសព្វផ្សេង ៗ ដូចជាក្នុងលោកនេះឡើយ ។

ក៏ឯពោធិបក្ខិយធម៌នោះមានចំនួន ៣៧ គឺសតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អង្គមគ្គ ៨ ត្រូវជា ៣៧ ។

## សតិបដ្ឋាន

សតិបដ្ឋាន ប្រែថា ទីតាំងនៅនៃស្មារតី ឬថាការតាំងនៅជាប្រធាននៃស្មារតី ឬថាទីឈរនៅនៃស្មារតី ហត្ថិដ្ឋានំ អស្សដ្ឋានន្តិ អាទីនិ វិយ ដូចគ្នានឹងពាក្យថាទីឈរនៅនៃដំរី ទីឈរនៅនៃសេះជាដើម ។

ឯសតិបដ្ឋាននេះមាន ៤ យ៉ាងគឺ កាយានុបស្សនាសតិ-បដ្ឋាន ទីតាំងនៅនៃស្មារតី ក្នុងការពិចារណាកាយ ១ វេទនា-

នុបស្សនាសតិបដ្ឋាន ទីតាំងនៅនៃស្មារតី ក្នុងការពិចារណាវេទនា ១ ចិត្តានុបស្សនាសតិបដ្ឋាន ទីតាំងនៅនៃស្មារតី ក្នុងការពិចារណាចិត្ត ១ ធម្មានុបស្សនាសតិបដ្ឋាន ទីតាំងនៅនៃស្មារតីក្នុងការពិចារណាធម៌ទាំងឡាយ ១ ។

## កាយានុបស្សនាសតិបដ្ឋាន

ពាក្យថា ទីតាំងនៅនៃស្មារតី ក្នុងការពិចារណាកាយនោះ កាយក្នុងទីនេះសំដៅយកអស្សាសបស្សាស គឺខ្យល់ដកដង្ហើមចេញ-ចូលម្យ៉ាង សំដៅយកឥរិយាបថម្យ៉ាង សំដៅយកកិច្ចទាំងពួងមានដើរឈានទៅមុខ ដើរឈានថយក្រោយជាដើមម្យ៉ាង សំដៅយកអាការទាំង ៣១ ឬ ៣២ មានសក់ជាដើមម្យ៉ាង សំដៅយកធាតុម្យ៉ាង សំដៅយកសាកអសុភដែលគេយកទៅចោលក្នុងព្រៃស្មសាន (ទីប៉ាឆា) មាន ៩ យ៉ាងម្យ៉ាង

កាយសំដៅយកអស្សាសបស្សាស គឺខ្យល់ដកដង្ហើមចេញ-ចូលនោះសេចក្ដីថាភិក្ខុក្នុងសាសនានេះស្ថិតនៅក្នុងទីដ៏សមគួរដល់ភាវនា គឺព្រៃក្ដី ម្លប់ឈើក្ដី ផ្ទះស្ងាត់ក្ដី អង្គុយពែនភ្នែន តាំងកាយឱ្យត្រង់ ប្រុងស្មារតីកំណត់ខ្យល់ដកដង្ហើមចេញ-

ចូល កាលបើដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលបើដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលបើដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី កាលបើដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកាយ គឺខ្យល់ដកដង្ហើមចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវកាយ គឺខ្យល់ដកដង្ហើមចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ គឺខ្យល់ដកដង្ហើមចេញ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ គឺខ្យល់ដកដង្ហើមចូល ហើយដកដង្ហើមចូល ។ ការកំណត់ពិចារណាសិក្សាដូច្នេះជាដើមហៅថាកាយានុបស្សនាសតិប្បដ្ឋាន បើនឹងហៅថា អានាបានស្សតិកម្មដ្ឋាន ដូច្នេះវិញក៏បាន ។

កាយសំដៅយកឥរិយាបថនោះ សេចក្ដីថា ភិក្ខុក្នុងសាសនានេះ កាលបើដើរ ក៏ដឹងច្បាស់ថា អាត្មាអញដើរ កាលបើឈរ ក៏ដឹងច្បាស់ថា អាត្មាអញឈរ កាលបើអង្គុយ

ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ កាលបើដេក ក៏ដឹងច្បាស់ថា អាត្មាអញដេក ឬថាភិក្ខុនោះដំកល់នៅកាយ គឺឥរិយាបថយ៉ាងណា ៗ ក៏ដឹងច្បាស់នូវកាយនោះយ៉ាងនោះ ៗ ដែរ ការកំណត់ដឹងឥរិយាបថដូច្នេះក៏ហៅថា កាយានុបស្សនាសតិបដ្ឋាន ។

កាយសំដៅយកកិច្ចទាំងពួងមានដើរឈានទៅមុខ ដើរឈានថយក្រោយជាដើមនោះ សេចក្ដីថា ភិក្ខុក្នុងសាសនានេះ ធ្វើសេចក្ដីដឹងខ្លួនក្នុងការដើរឈានទៅមុខ ដើរឈានថយក្រោយ ក្រឡេកចំ ក្រឡេកចំហៀង បត់ដៃជើងចូល លាដៃជើងចេញ ប្រើប្រាស់សង្ឃាដីបាត្រចីវរ បរិភោគភោជន ផឹកទឹក ទំពាស៊ីខាទនីយ លិទ្ធផ្លាប់សាយនីយ បន្ទោបង់មូត្រលាមក ដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់រលឹក និយាយស្រដី ស្ងៀមមិននិយាយ ធ្វើនូវសេចក្ដីដឹងខ្លួនក្នុងកិច្ចទាំងពួងដូច្នេះក៏ហៅថាកាយានុបស្សនាសតិបដ្ឋាន ។

កាយសំដៅយកអាការទាំង ៣១ ឬ ៣២ មានសក់ជាដើមនោះ សេចក្ដីថា ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយនេះ តាំងអំពីផ្ទៃជើងឡើងទៅលើ តាំងអំពីចុងសក់ចុះមក

ក្រោម មានស្បែកស្រោបជុំវិញដ៏ពេញទៅដោយអាការមិនស្អាត គួរខ្ពើមរអើមមានប្រការផ្សេងៗអាការដែលមានក្នុងកាយនេះគឺ សក់ រោម ក្រចក ធ្មេញ ស្បែក, សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹងទាប, បេះដូង ថ្លើម វាវ ក្រពះ សួត, ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ (ខួរក្នុងក្បាល), ប្រមាត់ ស្លេស ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់, ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។ ការពិចារណាកាយ គឺអាការមិនស្អាតគួរខ្ពើមរអើមដូច្នេះ ក៏ហៅថាកាយានុបស្សនាសតិបដ្ឋាន បើនឹងហៅថាកាយគតាសតិកម្មដ្ឋានដូច្នេះវិញក៏បាន ។

កាយសំដៅយកធាតុនោះ សេចក្តីថា ភិក្ខុក្នុងសាសនានេះ ពិចារណាកាយនេះ ដោយកំណត់ថាគ្រាន់តែជាធាតុទាំង ៤ គឺ ធាតុដី ១ ធាតុទឹក ១ ធាតុភ្លើង ១ ធាតុខ្យល់ ១ ។ ការពិចារណាកាយ គឺធាតុដូច្នេះក៏ហៅថា កាយានុបស្សនាសតិបដ្ឋាន បើនឹងហៅថាធាតុវវត្ថានកម្មដ្ឋានដូច្នេះវិញក៏បាន ។

កាយសំដៅយកសាកអសុភ ដែលគេយកទៅចោលក្នុងព្រៃស្មសាន (ទីប៉ាឆា) មាន ៩ យ៉ាងនោះគឺ សាកអសុភដែលគេយកទៅចោលក្នុងព្រៃស្មសាន ស្លាប់ ១ ថ្ងៃក្តី ២ ថ្ងៃក្តី ៣ ថ្ងៃក្តី ហើមឡើង មានសម្បុរខៀវ មានទឹកខ្ទុះហូរចេញ ១ សាកអសុភដែលមានសត្វក្អែកត្មាតខ្លែងជាដើមចឹកស៊ីទំពាស៊ីជាអាហារ ១ សាកអសុភដែលនៅរាងឆ្អឹង នៅមានសាច់ឈាមនិងសរសៃជាប់នៅ ១ សាកអសុភរាងឆ្អឹងគ្មានសាច់នៅមានឈាមប្រឡាក់និងមានសរសៃជាប់នៅ ១ សាកអសុភរាងឆ្អឹងគ្មានសាច់គ្មានឈាម នៅមានសរសៃជាប់នៅ ១ សាកអសុភនៅតែឆ្អឹងទទេគ្មានសរសៃ ឆ្អឹងនោះរាត់រាយខ្ចាត់ខ្ចាយទៅគ្រប់ទិស គឺឆ្អឹងដៃនៅទីដៃ ឆ្អឹងជើងនៅទីជើង ឆ្អឹងស្នង ឆ្អឹងភ្លៅ ឆ្អឹងចង្កេះ ឆ្អឹងខ្នង ឆ្អឹងទ្រនុងខ្នង ឆ្អឹងជំនីរ ឆ្អឹងទ្រូង ឆ្អឹងដើមដៃ ឆ្អឹងក ឆ្អឹងចង្កា ឆ្អឹងធ្មេញ ឆ្អឹងរលាក្បាល នៅផ្សេងៗពីគ្នាទាំងអស់ ១ សាកអសុភនៅតែឆ្អឹងទទេ មានសម្បុរសដូចជាសម្បុរសង្ខ ១ សាកអសុភនៅតែឆ្អឹងជាគំនរកន្លងទៅ ១ ឆ្នាំហើយ ១ សាកអសុភនៅតែឆ្អឹងពុកផុយនៅកំទេចឆ្អឹងល្អិតៗ ១ សាកអសុភទាំង ៩ នេះ ត្រូវ

ពិចារណាមើលឲ្យជាក់ច្បាស់ ហើយប្រៀបធៀបនឹងកាយរបស់ខ្លួនថា កាយយើងនេះក៏ដូចជាសាកអសុភនោះដែរ ។ ការពិចារណាដូច្នេះក៏ហៅថាកាយានុបស្សនាសតិបដ្ឋាន បើនឹងហៅថាអសុភកម្មដ្ឋានដូច្នេះវិញក៏បាន ។

ចប់កាយានុបស្សនាសតិបដ្ឋាន ។

## វេទនានុបស្សនាសតិបដ្ឋាន

ទីតាំងនៅនៃស្មារតី ក្នុងការពិចារណាវេទនា វេទនាមាន ៣ ប្រការគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ សេចក្ដីថា ភិក្ខុក្នុងសាសនានេះ កាលបើសោយវេទនាជាសុខ ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាជាសុខ កាលបើសោយវេទនាជាទុក្ខ ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាជាទុក្ខ កាលបើសោយវេទនាមិនមែនទុក្ខ មិនមែនសុខ គឺជាឧបេក្ខា ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាមិនមែនទុក្ខមិនមែនសុខ កាលបើសោយវេទនាជាសុខប្រកបដោយអាមិស[1] ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាជាសុខប្រកបដោយ

១ សោមនស្សវេទនា អាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦ ។

អាមិស កាលបើសោយវេទនាជាសុខប្រាសចាកអាមិស[១] ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាជាសុខប្រាសចាកអាមិស កាលបើសោយវេទនាជាទុក្ខប្រកបដោយអាមិស[២] ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាជាទុក្ខប្រកបដោយអាមិស កាលបើសោយវេទនាជាទុក្ខប្រាសចាកអាមិស[៣] ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាជាទុក្ខប្រាសចាកអាមិស កាលបើសោយវេទនាមិនមែនទុក្ខមិនមែនសុខប្រកបដោយអាមិស[៤] ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាមិនមែនទុក្ខមិនមែនសុខប្រកបដោយអាមិស កាលបើសោយវេទនាមិនមែនទុក្ខមិនមែនសុខប្រាសចាកអាមិស[៥] ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាមិនមែនទុក្ខមិនមែនសុខ ប្រាសចាកអាមិស ។ ការកំណត់ពិចារណាស្គាល់ច្បាស់ក្នុងវេទនាដូច្នេះ ហៅថាវេទនានុបស្សនាសតិបដ្ឋាន ។

ចប់ វេទនានុបស្សនាសតិបដ្ឋាន ។

---

១ សោមនស្សវេទនា អាស្រ័យនូវនេក្ខម្មប្រព្រឹត្តនៅក្នុងទ្វារ ៦ ។ ២ ទោមនស្សវេទនា អាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦ ។ ៣ ទោមនស្សវេទនា អាស្រ័យនេក្ខម្ម ប្រព្រឹត្តទៅក្នុងទ្វារ ៦ ។ ៤ ឧបេក្ខាវេទនា អាស្រ័យកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦ ។ ៥ ឧបេក្ខាវេទនា អាស្រ័យនេក្ខម្មប្រព្រឹត្តទៅក្នុងទ្វារ ៦ ។

## ចិត្តានុបស្សនាសតិបដ្ឋាន

ទីតាំងនៅនៃស្មារតី ក្នុងការពិចារណាចិត្តនោះ សេចក្ដីថា ភិក្ខុក្នុងសាសនានេះ កាលបើចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈហើយ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈហើយ ចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តប្រាសចាកទោសៈហើយ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈហើយ ចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈហើយ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈហើយ ចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា ចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដល់នូវសភាពជាធំ (រូបាវចរចិត្ត អរូបាវចរចិត្ត) ក៏ដឹងច្បាស់ថា ចិត្តដល់នូវសភាពជាធំ ចិត្តមិនទាន់ដល់នូវសភាពជាធំ (កាមាវចរចិត្ត) ក៏ដឹងច្បាស់ថា ចិត្តមិនទាន់ដល់នូវសភាពជាធំ ចិត្តជាសឧត្តរ នៅមានចិត្តដទៃលើសលប់ជាង (កាមាវចរចិត្ត) ក៏ដឹងច្បាស់ថា ចិត្តជាសឧត្តរ ចិត្តជាអនុត្តរ ឥតមានចិត្តដទៃលើសលប់ជាង (រូបាវចរចិត្តអរូបាវចរចិត្ត) ក៏ដឹងច្បាស់ថា

ចិត្តជាអនុត្តរ ចិត្តតាំងនៅមាំ (ឧបចារសមាធិអប្បនាសមាធិ) ក៏ដឹងច្បាស់ថា ចិត្តតាំងនៅមាំ ចិត្តមិនទាន់តាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់តាំងនៅមាំ ចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។ ពាក្យថាចិត្តរួចស្រឡះនោះ គឺចិត្តដែលប្រកបដោយវិមុត្តិ ២ ប្រការគឺ តទង្គវិមុត្តិ ១ វិក្ខម្ភនវិមុត្តិ ១ អនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ហៅថា តទង្គវិមុត្តិ ព្រោះរួចស្រឡះចាកនិច្ចសញ្ញា គឺសេចក្តីសំគាល់ថាទៀង តាមទំនងដែលព្រះយោគីបានកំណត់ដោយអង្គនៃធម៌ជាសត្រូវដល់ធម៌នោះៗ ។ សមាបត្តិ ៨ ហៅថា វិក្ខម្ភនវិមុត្តិ ព្រោះរួចចាកអកុសលធម៌មាននីវរណៈជាដើម តាមទំនងដែលព្រះយោគីបានសង្កត់សង្កិនដោយខ្លួនឯង ។ ការកំណត់ពិចារណាដឹងច្បាស់នូវចិត្តដូច្នេះ ហៅថា ចិត្តានុបស្សនា-សតិបដ្ឋាន ។

ចប់ចិត្តានុបស្សនាសតិបដ្ឋាន ។

## ធម្មានុបស្សនាសតិបដ្ឋាន

ទីតាំងនៅនៃស្មារតី ក្នុងការពិចារណាធម៌ ធម៌នោះសំដៅ

យកធម៌ ៥ ពួកគឺ នីវរណពួក ១ ឧបាទានក្ខន្ធពួក ១ អាយតនពួក ១ ពោជ្ឈង្គពួក ១ អរិយសច្ចពួក ១

ធម៌សំដៅយកនីវរណនោះ នីវរណមាន ៥ យ៉ាងគឺ កាមច្ឆន្ទ សេចក្តីប្រាថ្នា សេចក្តីស្រឡាញ់ពេញចិត្តក្នុងកាម ១ ព្យាបាទ ការញាំងប្រយោជន៍និងសេចក្តីសុខរបស់អ្នកដទៃឲ្យវិនាស ១ ថីនមិទ្ធ ប្រអូសចិត្តប្រអូសកាយគឺៈសេចក្តីខ្ជិល ១ ឧទ្ធច្ចកុក្កុច្ច សេចក្តីរាយមាយក្តៅក្រហាយរង្កៀស ១ វិចិកិច្ឆា សេចក្តីសង្ស័យ ១ មានសេចក្តីថា ភិក្ខុក្នុងសាសនានេះ កាលបើកាមច្ឆន្ទមាននៅក្នុងសន្តាន ក៏ដឹងច្បាស់ថា កាមច្ឆន្ទមាននៅក្នុងសន្តានអាត្មាអញ, កាលបើកាមច្ឆន្ទមិនមាននៅក្នុងសន្តានទេ ក៏ដឹងច្បាស់ថា កាមច្ឆន្ទមិនមាននៅក្នុងសន្តានអាត្មាអញទេ, ដឹងច្បាស់នូវហេតុ(១)ដែលនាំឲ្យកើតកាមច្ឆន្ទ និងហេតុ(២)ដែលនាំ

---

១ ការធ្វើទុកក្នុងចិត្តដោយមិនមែនជាឧបាយ ចំពោះសុភនិមិត្តឬចំពោះសភាវមិនទៀងថាទៀង ទុក្ខថាសុខ មិនមែនខ្លួនថាខ្លួន ។ ២ ការធ្វើទុកក្នុងចិត្តដោយឧបាយ ចំពោះសភាវមិនទៀងថាមិនទៀងមែន ទុក្ខថាទុក្ខមែន មិនមែនខ្លួនថាមិនមែនខ្លួនពិត និងធម៌ ៦ ប្រការ គឺរៀននូវអសុភនិមិត្ត ១ ប្រកបរឿយៗនូវការចំរើនអសុភ ១ គ្រប់គ្រងទ្វារដោយល្អក្នុងឥន្ទ្រិយទាំងប្រាំមួយ ១ ដឹងប្រមាណក្នុងភោជន ១ រាប់រកកល្យាណមិត្ត ១ និយាយពាក្យជាទីសប្បាយ ១ ។

ឲ្យលះបង់នូវកាមច្ឆន្ទបាននឹងហេតុ(១)ដែលនាំមិនឲ្យកាមច្ឆន្ទកើតឡើងតទៅទៀតបាន ។ កាលបើព្យាបាទមាននៅក្នុងសន្ដានក៏ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងសន្ដានអាត្មាអញ. កាលបើព្យាបាទមិនមាននៅក្នុងសន្ដានទេក៏ដឹងច្បាស់ថាព្យាបាទមិនមាននៅក្នុងសន្ដានអាត្មាអញទេ. ដឹងច្បាស់នូវហេតុ(២)ដែលនាំឲ្យកើតព្យាបាទ នឹងហេតុ(៣)ដែលនាំឲ្យលះបង់នូវព្យាបាទបាន នឹងហេតុ(៤)ដែលនាំមិនឲ្យកើតព្យាបាទតទៅទៀតបាន ។ កាលបើថីនមិទ្ធមាននៅក្នុងសន្ដាន ក៏ដឹងច្បាស់ថា ថីនមិទ្ធមាននៅក្នុងសន្ដានអាត្មាអញ. កាលបើថីនមិទ្ធមិនមាននៅក្នុងសន្ដានទេក៏ដឹងច្បាស់ថា ថីនមិទ្ធមិនមាននៅក្នុងសន្ដានអាត្មាអញទេ. ដឹងច្បាស់នូវហេតុ(៥)ដែលនាំឲ្យកើតថីនមិទ្ធ នឹងហេតុ(៦)ដែលនាំ-

---

១ អរហត្តមគ្គ ។ ២ ការធ្វើទុកក្នុងចិត្តដោយមិនមែនជាឧបាយ ចំពោះបដិឃនិមិត្តគឺអារម្មណ៍ដែលទាំងខ្ទប់ចិត្ត ។ ៣ ការធ្វើទុកក្នុងចិត្តដោយឧបាយចំពោះមេត្តាជាចេតោវិមុត្តិគឺមេត្តាចិត្តដែលបានអប្បនាឈាននឹងធម៌ ៦ ប្រការ គឺ រៀនមេត្តានិមិត្ត១ ប្រកបរឿយៗនូវការចំរើនមេត្តា១ ពិចារណានូវសភាពនៃសត្វមានកម្មជារបស់ខ្លួន១ ភាវជាអ្នកច្រើនដោយការពិចារណា១ រាប់រកកល្យាណមិត្ត១ និយាយពាក្យជាទីសប្បាយ១ ។ ៤ អនាគាមិមគ្គ ។ ៥ ធម៌ ៥ ប្រការគឺ មិនត្រេកអរ ឬអផ្សុក១ ច្រអូសឬទម្រន់កាយ១ មិតពត់កាយ១ ពុលបាយ១ រួញចិត្ត១ ។ ៦ ព្យាយាម ៣ យ៉ាងគឺ ព្យាយាមដែលប្រារព្ធឡើងជាដំបូង១ ព្យាយាមយ៉ាងកណ្ដាលៈ ជាគ្រឿងចេញចាកកោសជ្ជ១ ព្យាយាមយ៉ាងក្រៃលែងដែលកន្លងរួចពាកកោសជ្ជ១ នឹងធម៌ ៦ ប្រការគឺ កាន់យកនិមិត្តក្នុងការបរិភោគហួសប្រមាណ១ ផ្លាស់ផ្លូវឥរិយាបថ១ ធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា១ នៅក្នុងឱកាសដែលស្រឡះ១ រាប់រកកល្យាណមិត្ត១ និយាយពាក្យជាទីសប្បាយ១ ។

ឲ្យលះបង់នូវថីនមិទ្ធបាន នឹងហេតុ(១)ដែលនាំមិនឲ្យកើតថីនមិទ្ធតទៅទៀតបាន ។ កាលបើឧទ្ធច្ចកុក្កុច្ចមាននៅក្នុងសន្តានក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចមាននូវក្នុងសន្តានអាត្មាអញ, កាលបើឧទ្ធច្ចកុក្កុច្ច មិនមាននៅក្នុងសន្តានទេ, ក៏ដឹងច្បាស់ថា ឧទ្ធច្ច-កុក្កុច្ច មិនមាននៅក្នុងសន្តានអាត្មាអញទេ, ដឹងច្បាស់នូវហេតុ(២)ដែលនាំឲ្យកើតឧទ្ធច្ចកុក្កុច្ច នឹងហេតុ(៣)ដែលនាំឲ្យលះបង់នូវឧទ្ធច្ច-កុក្កុច្ចបាន នឹងហេតុ(៤)ដែលនាំមិនឲ្យកើតឧទ្ធច្ចកុក្កុច្ចតទៅទៀតបាន ។ កាលបើវិចិកិច្ឆាមាននៅក្នុងសន្តាន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងសន្តានអាត្មាអញ, កាលបើវិចិកិច្ឆាមិនមាននៅក្នុងសន្តានទេ ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងសន្តានអាត្មាអញទេ, ដឹងច្បាស់នូវហេតុ(៥)ដែលនាំឲ្យកើតវិចិ-

---

១ អរហត្តមគ្គ ។ ២ ការធ្វើទុកក្នុងចិត្តដោយមិនមែនជាឧបាយ ចំពោះធម៌ដែលមិនមែនជាគ្រឿងរម្ងាប់ចិត្ត ។ ៣ ការធ្វើទុកក្នុងចិត្តដោយឧបាយ ចំពោះធម៌ដែលជាគ្រឿងរម្ងាប់ចិត្ត នឹងធម៌ ៦ ប្រការគឺ ការចេះដឹងធម៌ច្រើន ១ ការសាកសួរ ១ ចេះដឹងស្ទាត់ក្នុងវិន័យ ១ សេពគប់នូវបុគ្គលដែលចំរើន ១ រាប់រកកល្យាណមិត្ត ១ និយាយពាក្យជាទីសប្បាយ ១ ។ ៤ ឧទ្ធច្ចមិនកើតតទៅទៀតដោយអរហត្តមគ្គ ឯកុក្កុច្ចមិនកើតតទៅទៀតដោយអនាគាមិមគ្គ ។ ៥ ការធ្វើទុកក្នុងចិត្តដោយមិនមែនជាឧបាយ ចំពោះធម៌ដែលជាទីតាំងនៃសេចក្តីសង្ស័យ ។

កិច្ឆា និងហេតុ[១]ដែលនាំឲ្យលះបង់នូវវិចិកិច្ឆាបាន និងហេតុ[២]ដែលនាំមិនឲ្យកើតវិចិកិច្ឆាតទៅទៀតបាន ។

ការកំណត់ពិចារណាដឹងច្បាស់នូវធម៌ គឺ នីវរណធម៌ប៉ុណ្ណេះ ហៅថាធម្មានុបស្សនាសតិបដ្ឋាន ។

ធម៌សំដៅយកឧបាទានក្ខន្ធនោះ ខន្ធដែលជាអារម្មណ៍របស់ឧបាទាន ឬខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គឺ កាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ ហៅថា ឧបាទានក្ខន្ធ ឬថាខន្ធដែលប្រកបដោយអាសវឧបាទាន ហៅថា ឧបាទានក្ខន្ធៗ នោះមាន ៥ ប្រការគឺ រូបូបាទានក្ខន្ធ១ វេទនូបាទានក្ខន្ធ១ សញ្ញូបាទានក្ខន្ធ១ សង្ខារូបាទានក្ខន្ធ១ វិញ្ញាណូបាទានក្ខន្ធ ១ សេចក្ដីថា ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញច្បាស់ថា រូបដូច្នេះ សេចក្ដីកើតឡើងនៃរូបដូច្នេះ សេចក្ដីរលត់ទៅនៃរូបដូច្នេះ, វេទនាដូច្នេះ សេចក្ដីកើតឡើងនៃវេទនាដូច្នេះ សេចក្ដី

---

១ ការធ្វើទុកក្នុងចិត្តដោយឧបាយ ចំពោះកុសលធម៌ជាដើម និងធម៌ ៦ ប្រការគឺ ការចេះដឹងធម៌ច្រើន ១ ការសាកសួរ ១ ចេះដឹងស្ទាត់ក្នុងវិន័យ ១ ការជាអ្នកច្រើនទៅដោយសេចក្ដីជឿស៊ប់ ១ រាប់រកកល្យាណមិត្ត ១ និយាយពាក្យជាទីសប្បាយ ១ ។ ២ វិចិកិច្ឆា មិនកើតតទៅទៀតដោយសោតាបត្តិមគ្គ ។

រលត់ទៅនៃវេទនាឈ្មោះ សញ្ញាឈ្មោះ សេចក្ដីកើតឡើងនៃសញ្ញាឈ្មោះ សេចក្ដីរលត់ទៅនៃសញ្ញាឈ្មោះ សង្ខារឈ្មោះ សេចក្ដីកើតឡើងនៃសង្ខារឈ្មោះ សេចក្ដីរលត់ទៅនៃសង្ខារឈ្មោះ វិញ្ញាណឈ្មោះ សេចក្ដីកើតឡើងនៃវិញ្ញាណឈ្មោះ សេចក្ដីរលត់ទៅនៃវិញ្ញាណឈ្មោះ ការកំណត់ពិចារណាដឹងច្បាស់នូវឧបាទានក្ខន្ធឈ្មោះ ក៏ហៅថាធម្មានុបស្សនាសតិបដ្ឋាន ។

ធម៌សំដៅយកអាយតននោះ អាយតន ប្រែថា ទីនៅ ជាអណ្ដូង ជាទីប្រជុំ ជាទីកើត ជាហេតុ គឺថាអាយតននោះជាទីនៅនៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដែលប្រព្រឹត្តទៅក្នុងទ្វារនោះ ៗ ដែលមានវត្ថុនោះ ៗ ជាអារម្មណ៍ ជាអណ្ដូងនៃវិញ្ញាណមានចក្ខុវិញ្ញាណជាដើម ដែលប្រព្រឹត្តទៅដោយដេរដាស ជាទីប្រជុំនៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដែលប្រជុំគ្នាតាមទ្វារនឹងអារម្មណ៍ ជាទីកើតនៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដែលកើតឡើងក្នុងទ្វារ នឹងអារម្មណ៍នោះ ៗ ជាហេតុនៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ឯអាយតននោះបាត់ជាខាងក្នុង ៦ តាមទ្វារ បាត់ជាខាងក្រៅ ៦

តាមអារម្មណ៍ ខាងក្នុង ៦ នោះគឺ ចក្ខុ ភ្នែក ១ សោតំ ត្រចៀក ១ ឃានំ ច្រមុះ ១ ជិវ្ហា អណ្តាត ១ កាយោ កាយ ១ មនោ ចិត្ត ១ ខាងក្រៅ ៦ នោះគឺ រូបំ រូប ១ សទ្ទោ សំឡេង ១ គន្ធោ ក្លិនកាយ ១ រសោ រសអាហារ ១ ផោដ្ឋព្វំ(១) ផោដ្ឋព្វ ១ ធម្មោ ធម៌ ១ ឯធម៌នោះ បានខាងចេតសិក ៥២ សុខុមរូប ១៦ និព្វាន ១ ត្រូវជា ៦៩ ។

សេចក្តីថា ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវភ្នែក ដឹងច្បាស់នូវរូប ដឹងច្បាស់នូវសញ្ញោជន(២)ដែលកើតឡើង ព្រោះអាស្រ័យភ្នែកនឹងរូបនោះ ជួបជុំគ្នា ដឹងច្បាស់នូវហេតុ(៣) ដែលនាំឲ្យ

---

១ បានខាងបឋវីធាតុ តេជោធាតុ វាយោធាតុ ។ ២ សញ្ញោជនៈមាន ១០ យ៉ាង គឺ កាមរាគ ១ បដិឃ ១ មានះ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ ភវរាគ ១ ឥស្សា ១ មច្ឆរិយ ១ អវិជ្ជា ១ ។ ៣ សញ្ញោជនទាំង ១០ នោះកើតឡើង ព្រោះអាស្រ័យហេតុផ្សេងៗពីគ្នា គឺ កាមរាគ តម្រេកដោយអំណាចកាមចំពោះអារម្មណ៍គួរប្រាថ្នាដែលមកកាន់តាមចក្ខុទ្វារ ។ បដិឃ សេចក្តីក្រោធចំពោះអារម្មណ៍ដែលមិនគួរប្រាថ្នា ។ មានះ សេចក្តីសំគាល់ថា បើក្រៅតែអំពីអញ មិនមានអ្នកណាមួយអាចចំរើននូវអារម្មណ៍នុះបានឡើយ ។ ទិដ្ឋិ សេចក្តីប្រកាន់ឬយល់ឃើញនូវរូបារម្មណ៍នុះថាទៀង ថាស្ថិតស្ថេរ ។ វិចិកិច្ឆា សេចក្តីសង្ស័យចំពោះរូបារម្មណ៍នុះ ថាជាសត្វ ឬថាជារបស់សត្វ ។ ភវរាគ សេចក្តីប្រាថ្នានូវភពថា ភពនេះយើងតែងបានដោយងាយក្នុងសម្បត្តិភព ។ សីលព្វតបរាមាស សេចក្តីប្រកាន់ខ្ជាប់នូវសីលនិងវត្តថា សីលនិងវត្តយ៉ាងនេះ យើងអាចសមាទានកាន់យកបាន ។ ឥស្សា សេចក្តីច្រណែនថា សូមកុំឲ្យជនដទៃបាននូវរូបារម្មណ៍នេះឡើយ ។ មច្ឆរិយ សេចក្តីកំណាញ់លាក់លៀមនូវរូបា-រម្មណ៍ដែលខ្លួនបានហើយ នឹងបុគ្គលដទៃ ។ អវិជ្ជា សេចក្តីមិនដឹងនូវសហជាតធម៌ទាំងអស់។

កើតសញ្ញោជនៈ ដឹងច្បាស់នូវហេតុ(១)ដែលនាំឲ្យលះបង់នូវសញ្ញោជនៈបាន ដឹងច្បាស់នូវហេតុ(២)ដែលនាំមិនឲ្យសញ្ញោជនៈកើតឡើងតទៅទៀតបាន ។ ដឹងច្បាស់នូវត្រចៀក ដឹងច្បាស់នូវសំឡេង ។ ដឹងច្បាស់នូវច្រមុះ ដឹងច្បាស់នូវក្លិន ដឹងច្បាស់នូវអណ្ដាត ដឹងច្បាស់នូវរស ។ ដឹងច្បាស់នូវកាយ ដឹងច្បាស់នូវផោដ្ឋព្វៈ ។ ដឹងច្បាស់នូវចិត្ត ដឹងច្បាស់នូវធម៌ទាំងឡាយ ដឹងច្បាស់នូវសញ្ញោជនៈ(៣)ដែលកើតឡើង ព្រោះអាស្រ័យចិត្តនឹងធម៌នោះផ្សំគ្នា ដឹងច្បាស់នូវហេតុដែលនាំឲ្យកើតសញ្ញោជនៈ ដឹងច្បាស់នូវហេតុដែលនាំឲ្យលះបង់នូវសញ្ញោជនៈបាន ដឹងច្បាស់នូវហេតុដែលនាំមិនឲ្យកើតសញ្ញោជនៈតទៅទៀតបាន ។

ការកំណត់ពិចារណាដឹងច្បាស់នូវអាយតនៈទាំង ១២ ដូច្នេះ ក៏ហៅថា ធម្មានុបស្សនាសតិប្បដ្ឋាន ។

---

១ លះបង់ដោយមគ្គ ២ យ៉ាង គឺ តទង្គប្បហាន ១ វិក្ខម្ភនប្បហាន ១ ។ ២ សញ្ញោជនៈ ៩ ប្រការគឺ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ ឥស្សា ១ មច្ឆរិយៈ ១ ដែលមិនកើតតទៅទៀត ដោយសោតាបត្តិមគ្គ ។ កាមរាគ នឹងបដិឃៈ ដែលជាចំណែកគ្រោតគ្រាត មិនកើតតទៅទៀត ដោយសកទាគាមិមគ្គ ដែលជាចំណែកល្អិត ឬ ស្រាលស្ដើង មិនកើតតទៅទៀត ដោយអនាគាមិមគ្គ មានៈ ១ ភវរាគ ១ អវិជ្ជា ១ ដែលមិនកើតតទៅទៀត ដោយអរហត្តមគ្គ ។ ៣ សញ្ញោជនៈដែលកើតអាស្រ័យត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ត្រូវដឹងតាមទំនងភ្នែកនឹងរូបខាងដើម ។

ធម៌សំដៅយកពោជ្ឈង្គនោះ ពោជ្ឈង្គ ប្រែថា ធម៌ជាអង្គ គឺ ជាហេតុរបស់បុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ពោជ្ឈង្គនោះមាន ៧ ប្រការ គឺ សតិសម្ពោជ្ឈង្គ ធម៌ជាហេតុរបស់បុគ្គលជាអ្នកត្រាស់ដឹង គឺ សតិ (ស្មារតី) ១ ធម្មវិចយសម្ពោជ្ឈង្គ ធម៌ជាហេតុរបស់បុគ្គលជាអ្នកត្រាស់ដឹង គឺ ធម្មវិចយ សភាវពិចារណានូវធម៌ បានដល់វិបស្សនាបញ្ញា ១ វីរិយសម្ពោជ្ឈង្គ ធម៌ជាហេតុរបស់បុគ្គលជាអ្នកត្រាស់ដឹង គឺ វីរិយ សេចក្តីព្យាយាម បីតិសម្ពោជ្ឈង្គ ធម៌ជាហេតុរបស់បុគ្គលជាអ្នកត្រាស់ដឹង គឺ បីតិ ធម្មជាតិញ៉ាំងកាយនិងចិត្តឲ្យឆ្អែត ឬថាឲ្យចំរើន ១ បស្សទ្ធិសម្ពោជ្ឈង្គ ធម៌ជាហេតុរបស់បុគ្គលជាអ្នកត្រាស់ដឹង គឺ បស្សទ្ធិ សេចក្តីស្ងប់រម្ងាប់កាយ(១)និងចិត្ត ១ សមាធិសម្ពោជ្ឈង្គ ធម៌ជាហេតុរបស់បុគ្គលជាអ្នកត្រាស់ដឹង គឺសមាធិ ចិត្តដែលតាំងនៅស៊ប់ក្នុងអារម្មណ៍ មានលក្ខណមិនរាយមាយ ១ ឧបេក្ខាសម្ពោជ្ឈង្គ ធម៌ជាហេតុរបស់បុគ្គលជាអ្នកត្រាស់ដឹង គឺឧបេក្ខា ឯឧបេក្ខានេះ ប្រែថា ព្រងើយ

---

១ បានដល់អរូបក្ខន្ធ ៣ មានវេទនាជាដើម ។

កន្ដើយ ជាក្រឡេកយកឬសំឡឹងមើល ដោយការដល់នូវសភាពនៃចិត្តជាកណ្ដាល បានដល់តត្រមជ្ឈត្តុបេក្ខា គឺជាឧបេក្ខា តាំងនៅជាកណ្ដាលក្នុងធម៌នោះៗ ។

សេចក្ដីក្នុងសត្តពោជ្ឈង្គនោះថា ភិក្ខុក្នុងសាសនានេះ កាលបើសតិសម្ពោជ្ឈង្គមាននៅក្នុងសន្ដាន ក៏ដឹងច្បាស់ថាសតិសម្ពោជ្ឈង្គមាននៅក្នុងសន្ដានអាត្មាអញ កាលបើសតិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្ដានទេ ក៏ដឹងច្បាស់ថាសតិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្ដានអាត្មាអញទេ ដឹងច្បាស់នូវហេតុ(១)ដែលនាំឲ្យកើតសតិសម្ពោជ្ឈង្គ ដឹងច្បាស់នូវហេតុ(២)ដែលនាំឲ្យសតិ-សម្ពោជ្ឈង្គ ដែលកើតហើយ បានពេញលេញដោយភាវនា ។

កាលបើធម្មវិចយសម្ពោជ្ឈង្គមាននៅក្នុងសន្ដាន ក៏ដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គមាននៅក្នុងសន្ដានអាត្មាអញ

---

១-២ ការធ្វើយោនិសោមនសិការឲ្យច្រើនទៅក្នុងសតិសម្ពោជ្ឈង្គនោះ ជាហេតុនាំឲ្យសតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ឬដែលកើតឡើងស្រាប់ហើយក៏រឹងរឹតតែចំរើនច្រើនឡើង ។

១ ទៀតធម៌ដែលជាហេតុឲ្យកើតសតិសម្ពោជ្ឈង្គនោះមាន ៤ យ៉ាង គឺត្រូវឲ្យមានសតិនិងសម្បជញ្ញក្នុងទីទាំង ៧ មានដើរឈានទៅមុខជាដើម ១ វៀរចាកបុគ្គលភ្លេចស្មារតី ១ រាប់រកបុគ្គលដែលមានស្មារតីខ្ជាប់ខ្ជួន ១ បង្អោនចិត្តទៅដើម្បីដំកល់សតិគ្រប់ឥរិយាបថ ១ ។

កាលបើ ធម្មវិចយសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានទេ ក៏ដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានអាត្មាអញទេ ដឹងច្បាស់នូវហេតុ(១)ដែលនាំឲ្យកើតធម្មវិចយសម្ពោជ្ឈង្គ ដឹងច្បាស់នូវហេតុដែលនាំឲ្យធម្មវិចយសម្ពោជ្ឈង្គ ដែលកើតហើយ បានពេញលេញដោយភាវនា ។

កាលបើវីរិយសម្ពោជ្ឈង្គមាននៅក្នុងសន្តាន ក៏ដឹងច្បាស់ថា វីរិយសម្ពោជ្ឈង្គមាននៅក្នុងសន្តានអាត្មាអញ កាលបើវីរិយ-សម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានទេ ក៏ដឹងច្បាស់ថាវីរិយសម្ពោ-ជ្ឈង្គមិនមាននៅក្នុងសន្តានអាត្មាអញទេ ដឹងច្បាស់នូវហេតុ(២)ដែលនាំឲ្យកើតវីរិយសម្ពោជ្ឈង្គ ដឹងច្បាស់នូវហេតុដែលនាំឲ្យវីរិយសម្ពោជ្ឈង្គដែលកើតហើយបានពេញលេញដោយភាវនា។

---

១– ធម៌ដែលជាហេតុនាំឲ្យកើតធម្មវិចយសម្ពោជ្ឈង្គមាន ៧ គឺ ការសាកសួរ ១ ធ្វើវត្ថុខាងក្នុងមានសក់រោមជាដើម និងវត្ថុខាងក្រៅមានចីវរសេនាសនៈជាដើមឲ្យស្អាតបាត ១ ប្រមូលផ្សំផ្សំឥន្ទ្រិយទាំង ៥ មានសតិន្ទ្រិយជាដើមឲ្យដើរស្មើគ្នា ១ វៀរចាកបុគ្គលដែលអាប់ឥតប្រាជ្ញា ១ រាប់រកបុគ្គលដែលមានប្រាជ្ញា ១ ពិចារណាចំពោះបញ្ហាក្តីជ្រាលជ្រៅដោយញាណចរិយា ១ បង្អោនចិត្តទៅដើម្បីបណ្តុះធម្មវិចយសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។ ២–ធម៌ជាហេតុនាំឲ្យកើតវីរិយសម្ពោជ្ឈង្គមាន ១១ គឺ ពិចារណាឃើញនូវភ័យក្នុងអបាយ ១ ឃើញនូវអានិសង្ស (នៃការព្យាយាម) ១ ពិចារណាឃើញនូវផ្លូវដែលត្រូវទៅ ១ កោតក្រែងចំពោះបិណ្ឌបាត ១ ពិចារណាឃើញនូវអរិយទ្រព្យទាំង ៧ ជាទ្រព្យមរតកធំ ១ – នូវព្រះសាស្តាជាធំ ១ – នូវជាតិជាធំ ១ – នូវសព្រហ្មចារីបុគ្គលជាធំ ១ – វៀរចាកបុគ្គលខ្ជិលច្រអូស ១ – រាប់រកបុគ្គលមានព្យាយាម ១ – បង្អោនចិត្តទៅដើម្បីបណ្តុះនូវវីរិយសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

កាលបើបីតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានក៏ដឹងច្បាស់ថាបីតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានអាត្មាអញ កាលបើបីតិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានទេ ក៏ដឹងច្បាស់ថា បីតិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានអាត្មាអញទេ ដឹងច្បាស់នូវហេតុដែល(១)នាំឲ្យកើតបីតិសម្ពោជ្ឈង្គ ដឹងច្បាស់នូវហេតុដែលនាំឲ្យបីតិសម្ពោជ្ឈង្គដែលកើតហើយ បានពេញលេញដោយភាវនា ។

កាលបើបស្សទ្ធិសម្ពោជ្ឈង្គមាននៅក្នុងសន្តាន ក៏ដឹងច្បាស់ថា បស្សទ្ធិសម្ពោជ្ឈង្គមាននៅក្នុងសន្តានអាត្មាអញ កាលបើបស្សទ្ធិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានទេ ក៏ដឹងច្បាស់ថា បស្សទ្ធិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានអាត្មាអញទេ ដឹងច្បាស់នូវហេតុដែល(២)នាំឲ្យកើតបស្សទ្ធិសម្ពោជ្ឈង្គ ដឹង

---

១ — ធម៌ជាហេតុនាំឲ្យកើតបីតិសម្ពោជ្ឈង្គមាន ១១ គឺ រឭកដល់ព្រះពុទ្ធ ១ — ព្រះធម៌ ១ ព្រះសង្ឃ ១ — សីល ១ — បរិច្ចាគ ១ — ធម៌នាំឲ្យកើតជាទេវតា ១ — ព្រះនិព្វាន ១ វៀរចាកបុគ្គលមិនស្អាតបាត ១ រាប់រកបុគ្គលស្អាតបាត ១ ពិចារណាតាមបសាទនីយសូត្រ ១ បង្អោនចិត្តទៅដើម្បីបណ្ដុះបីតិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។ ២ — ធម៌ជាហេតុនាំឲ្យកើតបស្សទ្ធិសម្ពោជ្ឈង្គមាន ៧ គឺ ត្រូវការភោជនថ្លៃថ្លា ១ ត្រូវការរដូវសប្បាយ ១ ត្រូវការឥរិយាបថសប្បាយ ១ ប្រកបខ្លួនឲ្យតាំងនៅជាកណ្ដាល ១ វៀរចាកបុគ្គលមានកាយរពឹស ១ រាប់រកបុគ្គលអ្នកមានកាយស្ងប់រម្ងាប់ ១ បង្អោនចិត្តទៅដើម្បីបណ្ដុះបស្សទ្ធិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

ច្បាស់នូវហេតុដែលនាំឲ្យបស្សទ្ធិសម្ពោជ្ឈង្គ ដែលកើតហើយ បានពេញលេញដោយភាវនា ។

កាលបើសមាធិសម្ពោជ្ឈង្គមាននៅក្នុងសន្តាន ក៏ដឹងច្បាស់ថា សមាធិសម្ពោជ្ឈង្គមាននៅក្នុងសន្តានអាត្មាអញ កាលបើសមាធិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានទេ ក៏ដឹងច្បាស់ថា សមាធិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានអាត្មាអញទេ [១]ដឹងច្បាស់នូវហេតុដែលនាំឲ្យកើតសមាធិសម្ពោជ្ឈង្គ ដឹងច្បាស់នូវហេតុដែលនាំឲ្យសមាធិសម្ពោជ្ឈង្គដែលកើតហើយ បានពេញលេញដោយភាវនា ។

កាលបើឧបេក្ខាសម្ពោជ្ឈង្គមាននៅក្នុងសន្តាន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមាននៅក្នុងសន្តានអាត្មាអញ កាលបើឧបេក្ខាសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានទេ ក៏ដឹង

---

១—ធម៌ជាហេតុនាំឲ្យកើតសមាធិសម្ពោជ្ឈង្គមាន ១១ គឺ ធ្វើវត្ថុខាងក្នុងនិងខាងក្រៅឲ្យស្អាត ១ ប្រមូលផ្ដុំឥន្ទ្រិយទាំង ៥ ឲ្យដើរស្មើគ្នា ១ ឈ្លាសវៃក្នុងកសិណនិមិត្ត ១ ផ្គងចិត្តឡើងតាមសម័យ ១ សង្កត់សង្កិនចិត្តតាមសម័យ ១ ធ្វើចិត្តឲ្យរីករាយដោយសង្វេគវត្ថុ ៨ ប្រការតាមសម័យ ១ ធ្វើចិត្តឲ្យស្ងប់ស្ងៀមនូវអារម្មណ៍ឬឲ្យព្រងើយកន្តើយក្នុងអារម្មណ៍ ១ វៀរចាកបុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន ១ គប់រកបុគ្គលដែលមានចិត្តខ្ជាប់ខ្ជួន ១ ពិចារណានូវឈានវិមោក្ខ ១ បង្អោនចិត្តទៅដើម្បីឲ្យកើតសមាធិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

ច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានអាត្មាអញទេ ដឹងច្បាស់នូវហេតុ[១]ដែលនាំឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គ ដឹងច្បាស់នូវហេតុដែលនាំឲ្យឧបេក្ខាសម្ពោជ្ឈង្គដែលកើតហើយបានពេញលេញដោយភាវនា ។

ការកំណត់ពិចារណាដឹងច្បាស់នូវពោជ្ឈង្គទាំង ៧ ដូច្នេះ ក៏ហៅថាធម្មានុបស្សនាសតិបដ្ឋាន ។

ធម៌សំដៅយកអរិយសច្ចនោះ អរិយសច្ចមាន ៤ យ៉ាងគឺៈ ទុក្ខអរិយសច្ច សេចក្ដីទុក្ខជាធម្មជាតពិតរបស់ព្រះអរិយបុគ្គល ១ ទុក្ខសមុទយអរិយសច្ច តណ្ហាជាហេតុឲ្យកើតទុក្ខជាធម៌ពិតរបស់ព្រះអរិយបុគ្គល ១ ទុក្ខនិរោធអរិយសច្ច សេចក្ដីរលត់នៃទុក្ខជាធម៌ពិតរបស់ព្រះអរិយបុគ្គល ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច សេចក្ដីប្រតិបត្តិញុំាងសត្វឲ្យដល់នូវសេចក្ដីរលត់នៃទុក្ខជាធម្មជាតិពិត របស់ព្រះអរិយបុគ្គល ១ ។

---

១ ធម៌ជាហេតុនាំឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គមាន ៥ គឺ ធ្វើចិត្តឲ្យតាំងនៅជាកណ្ដាលចំពោះសត្វ ១ ធ្វើចិត្តឲ្យតាំងនៅជាកណ្ដាលចំពោះសង្ខារ ១ វៀរចាកបុគ្គលដែលមានការទំនុកបំរុងរាប់អានថ្នាក់ថ្នមសត្វនិងសង្ខារ ១ រាប់រកបុគ្គលដែលមានចិត្តជាកណ្ដាលចំពោះសត្វនិងសង្ខារ ១ បង្អោនចិត្តទៅដើម្បីឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

សេចក្ដីថា ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថានេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថានេះជាសេចក្ដីរលត់ទុក្ខ ដឹងច្បាស់តាម ពិតថានេះជាសេចក្ដីប្រតិបត្តិ ញ៉ាំងសត្វឲ្យដល់នូវសេចក្ដី រលត់ទុក្ខ ។

## ទុក្ខអរិយសច្ច

ទុក្ខអរិយសច្ច ព្រះដ៏មានព្រះភាគទ្រង់សំដែង ដោយ សេចក្ដីទុក្ខច្រើនប្រការដូចតទៅនេះ ជាតិ សេចក្ដីកើតជាទុក្ខ១ ជរា សេចក្ដីចាស់គ្រាំគ្រាជាទុក្ខ ១ មរណៈ សេចក្ដីស្លាប់ជា ទុក្ខ ១ សោកៈ សេចក្ដីក្ដៅក្រហាយចិត្ត របស់សត្វដែល មានសេចក្ដីវិនាសញាតិជាដើមមកពាល់ត្រូវជាទុក្ខ ១ បរិទេវៈ សេចក្ដីខ្សឹកខ្សួលយំស្រែកជាទុក្ខ ១ ទុក្ខៈ សេចក្ដីលំបាកកាយ ជាទុក្ខ ១ ទោមនស្សៈ សេចក្ដីលំបាកចិត្តជាទុក្ខ ១ ឧបាយាសៈ សេចក្ដីចង្អៀតចង្អល់ចិត្តខ្លាំងជាទុក្ខ ១ អប្បិយេហិសម្បយោគៈ ការជួបប្រសព្វដោយសត្វនឹងសង្ខារមិនជាទីស្រឡាញ់ជាទុក្ខ១ បិយេហិវិប្បយោគៈ ព្រាត់ប្រាស់ចាកសត្វនឹងសង្ខារជាទី

ស្រឡាញ់ជាទុក្ខ ១ យម្បិច្ឆំ ន លភតិ ប្រាថ្នារបស់ឯណាមិនបានរបស់នោះ ជាទុក្ខ ១ បើនិយាយដោយសង្ខេបទៀតថា ឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ។

### ទុក្ខសមុទយអរិយសច្ច

ទុក្ខសមុទយអរិយសច្ចនោះ ព្រះដ៏មានព្រះភាគទ្រង់សំដែងដោយតណ្ហា ៣ ប្រកា និងតណ្ហា ១២ ប្រការ ឯតណ្ហា ៣ ប្រការនោះ គឺ កាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកាម បានខាងរាគៈ គឺសេចក្ដីត្រេកអរប្រកបដោយកាមគុណទាំងប្រាំ ១ ភវតណ្ហា សេចក្ដីប្រាថ្នាក្នុងភព បានខាងរាគៈ គឺ សេចក្ដីត្រេកអរក្នុងរូបភពនិងអរូបភព ជារាគៈ កើតឡើងដោយអំណាចនៃសេចក្ដីប្រាថ្នានូវភព ជារាគៈ ប្រកបដោយសស្សតទិដ្ឋិ ១ ទៀតភវតណ្ហានេះ បានខាងសេចក្ដីអាល័យក្នុងឈាន ១ វិភវតណ្ហា សេចក្ដីប្រាថ្នាក្នុងភពសូន្យ បានខាងរាគៈ ប្រកបដោយឧច្ឆេទទិដ្ឋិ ១ ។

ឯតណ្ហា ១២ ប្រការនោះគឺ ចក្ខុតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីឆ្ងាញ់ពិសាចំពោះភ្នែក រាប់អានថាជារបស់ខ្លួន សំ-

គាល់ហាដូចជាបង្អួចកែវមណី ដែលគេបើកក្នុងវិមានមាស ១ សោតតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះត្រចៀក រាប់អានថាជារបស់ខ្លួន សំគាល់ហាដូចជាបំពង់ប្រាក់នឹងខ្សែសង្វារ ១ ឃានតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះច្រមុះរាប់អានថាជារបស់ខ្លួន សំគាល់ហាដូចជាខ្សែប្រហរីតាលដែលគេវេញហើយដំកល់ទុក ១ ជិវ្ហាតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះអណ្ដាត រាប់អានថាជារបស់ខ្លួន សំគាល់ហាដូចជាផែនសំពត់កម្ពលក្រហម ១ កាយតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះកាយរាប់អានថាជារបស់ខ្លួន សំគាល់ហាដូចជាសសរឈើខ្លឹម នឹងសសរខ្លោងទ្វារជាវិការនៃមាស ១ មនោតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះចិត្ត រាប់អានថាជារបស់ខ្លួន សំគាល់ចិត្តខ្លួនថាវិសេសវិសាលជាងចិត្តអ្នកដទៃ ១ រូបតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះរូបារម្មណ៍ សំគាល់ហាដូចជាផ្កាកណ្ណិការមាសជាដើម ១ សទ្ទតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះសទ្ទារម្មណ៍ សំគាល់ហាដូចជាសំឡេង

សត្វករវិក សំឡេងសត្វតាវ៉ៅ សំឡេងស្រីឡៀកែវមណី ដែលគេផ្លុំប៉ាក់ប៉ូមផាដើម ១ គន្ធតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះគន្ធារម្មណ៍ សំគាល់គន្ធារម្មណ៍ដែលខ្លួនបានហើយថាគេមិនមានគន្ធារម្មណ៍ដូចយើងឡើយ ១ រសតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះរសារម្មណ៍ សុំ-គាល់រសារម្មណ៍ដែលខ្លួនបានហើយ ថាគេមិនមានរសារម្មណ៍ដូចយើងឡើយ ១ ផោដ្ឋព្វតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពីសាបំពោះផោដ្ឋព្វារម្មណ៍ សំគាល់ផោដ្ឋព្វារម្មណ៍ដែលខ្លួនបានហើយ ថាគេមិនមានផោដ្ឋព្វារម្មណ៍ដូចយើងឡើយ ១ ធម្មតណ្ហា សេចក្ដីស្រឡាញ់ សេចក្ដីផ្ទាញ់ពិសាបំពោះធម្មា-រម្មណ៍ សំគាល់ធម្មារម្មណ៍ដែលខ្លួនបានហើយថាគេមិនមានធម្មារម្មណ៍ដូចយើងឡើយ ១ ។ តណ្ហា ១២ ប្រការខាងចុងនេះយកទៅគុណនឹងតណ្ហា ៣ ប្រការខាងដើមត្រូវជាតណ្ហា ៣៦ ចាត់ជាអតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ ត្រូវជាតណ្ហា ១០៨ ហោង ។ ៕

### ទុក្ខនិរោធអរិយសច្ច

សេចក្ដីវិនាសទៅ សេចក្ដីរលត់ទៅនៃតណ្ហានោះ ការលះបង់ ការលះបោលនូវតណ្ហានោះ សេចក្ដីរួចចាកតណ្ហានោះ សេចក្ដីមិនអាល័យក្នុងតណ្ហានោះ ហៅថាទុក្ខនិរោធអរិយសច្ច ។

### ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច

សេចក្ដីប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វានជាគ្រឿងរលត់នៃទុក្ខ ជាអរិយសច្ច បានខាងមគ្គដ៏ប្រសើរប្រកបដោយអង្គ៨ គឺសម្មាទិដ្ឋិ សេចក្ដីយល់ត្រូវ១ សម្មាសង្កប្ប សេចក្ដីត្រិះរិះត្រូវ១ សម្មាវាចា និយាយត្រូវ១ សម្មាកម្មន្ត ការងារត្រូវ១ សម្មាអាជីវ ការចិញ្ចឹមជីវិតត្រូវ១ សម្មាវាយាម ព្យាយាមត្រូវ១ សម្មាសតិ សេចក្ដីរឭកត្រូវ១ សម្មាសមាធិ ការដំកល់ចិត្តត្រូវ១ ត្រូវជា៨ ។ ការកំណត់ពិចារណាដឹងច្បាស់នូវអរិយសច្ចទាំង៤ដូច្នេះ ក៏ហៅថា ធម្មានុបស្សនាសតិបដ្ឋាន ។

ចប់សតិបដ្ឋាន ។

### សម្មប្បធាន

សម្មប្បធាន ប្រែថា ធម្មជាតជាគ្រឿងដំកល់ទុកដោយប្រពៃ បានខាងសេចក្ដីព្យាយាមត្រូវ ឬល្អ មាន៤ យ៉ាងគឺ

ព្យាយាមដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ១ ព្យាយាមដើម្បីបិទបាំងអកុសលធម៌ដ៏លាមកដែលមិនទាន់កើតឡើង កុំឲ្យកើតឡើងបាន ១ ព្យាយាមដើម្បីបណ្តុះបណ្តាលកុសលធម៌ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ១ ព្យាយាមដើម្បីចំរើនកុសលធម៌ ដែលកើតស្រាប់ហើយ ឲ្យរីងរឹតតែច្រើនឡើង ១ ។

ចប់សម្មប្បធាន ។

ឥទ្ធិបាទ

ឥទ្ធិបាទ ប្រែថា ចំណែកគឺឫទ្ធិ ឬថាទីតាំងនៃឫទ្ធិ ឧបាយជាគ្រឿងដល់នូវឫទ្ធិ ឥទ្ធិបាទនេះមាន ៤ យ៉ាងគឺ ឆន្ទិទ្ធិបាទ ១ វិរិយិទ្ធិបាទ ១ ចិត្តិទ្ធិបាទ ១ វីមំសិទ្ធិបាទ ១ ។

ឆន្ទិទ្ធិបាទ ប្រែថា ឥទ្ធិបាទគឺឆន្ទៈ ឬថាឆន្ទៈ ជាឥទ្ធិបាទ ឆន្ទៈ សេចក្តីស្រឡាញ់ពេញចិត្ត គាប់ចិត្តក្នុងកុសលធម៌ ។

វិរិយិទ្ធិបាទ ប្រែថា ឥទ្ធិបាទគឺវិរិយៈ ឬថា វិរិយៈ ជាឥទ្ធិបាទ វិរិយៈ គឺសេចក្តីព្យាយាម ឧហាតស៏ង្វាតមិនខ្ជិលច្រអូសក្នុងកុសលធម៌ ។

ចិត្តិទ្ធិបាទ ប្រែថា ឥទ្ធិបាទគឺចិត្ត ឬថា ចិត្តជាឥទ្ធិបាទ ចិត្តៈ គឺសេចក្ដីគិត សេចក្ដីដឹងអារម្មណ៍ គំនិតរិះរេបែរទៅរកផ្លូវល្អ ផ្លូវត្រាស់ដឹងមគ្គផល ។

វីមំសិទ្ធិបាទ ប្រែថា ឥទ្ធិបាទគឺវីមំសា ឬថា វីមំសាជាឥទ្ធិបាទ វីមំសា គឺបញ្ញា សេចក្ដីដឹងច្បាស់ ។

១ទៀត ឆន្ទៈ វីរិយៈ និងវីមំសានេះជាតួចេតសិក ឆន្ទៈនិងវីរិយៈ នៅក្នុងពួកអញ្ញសមានចេតសិកទាំង ១៣ ជាចេតសិកដែលទៅខាងបាបក៏បាន ខាងបុណ្យក៏បាន ឆន្ទៈ សេចក្ដីស្រឡាញ់ ពេញចិត្ត គាប់ចិត្ត ចំពោះបាបក៏មាន ចំពោះបុណ្យក៏មាន វីរិយៈ សេចក្ដីព្យាយាមចំពោះបាបក៏មាន ចំពោះបុណ្យក៏មាន តែក្នុងទីនេះសំដៅយកបុណ្យតែម្យ៉ាង ចំណែកវីមំសាគឺបញ្ញានៅក្នុងពួកសោភណចេតសិកទាំង ២៥ ជាចំណែកខាងបុណ្យតែម្យ៉ាង បើនិយាយតាមន័យ ចេតសិកទាំង ៣ នេះរាប់ចូលក្នុងសង្ខារក្ខន្ធ ចំណែកចិត្តក៏ជាបាបក៏មាន បុណ្យក៏មាន តែក្នុងទីនេះសំដៅយកចិត្តបុណ្យ ចិត្តដែលបាញ់ទៅរកផ្លូវត្រាស់ដឹងមគ្គផលនិព្វាន បើនិយាយតាមន័យវិញ ចិត្តនេះជាតួវិញ្ញាណក្ខន្ធ ។

ធម៌ទាំង ៤ យ៉ាងនេះ បើបុគ្គលឯណាបានចំរើនដោយប្រពៃហើយ បុគ្គលនោះនឹងបានសម្រេចឫទ្ធិ សម្រេចគុណធម៌ដ៏ខ្ពង់ខ្ពស់តាំងអំពីបឋមជ្ឈានឡើងទៅ បណ្តាធម៌ទាំង ៤ នេះ សូម្បីតែ ១ ក៏អាចឲ្យសម្រេច លោកុត្តរធម៌បាន ។

តាមន័យដែលមានមកក្នុងគម្ពីរសម្មោហវិនោទនី លោកនិយាយអំពីភិក្ខុ ៤ អង្គរៀនកម្មដ្ឋានបានសម្រេចដូចគ្នា ភិក្ខុ ១ អង្គអាស្រ័យ ឆន្ទៈ ជាទីពឹងផ្អែក គិតថាអាត្មាអញនឹងញ៉ាំងលោកុត្តរធម៌ឲ្យកើតដោយកុសលធម្មច្ឆន្ទៈ គឺសេចក្តីពេញចិត្តចំពោះកុសលធម៌, ហើយក៏ធ្វើឆន្ទៈ ឲ្យជាធំ ឲ្យជាធុរៈ ឲ្យជាប្រធាន ក៏បានសម្រេចលោកុត្តរធម៌ ។ ភិក្ខុ ១ អង្គទៀត អាស្រ័យវីរិយៈ ។ ភិក្ខុ ១ អង្គទៀត អាស្រ័យចិត្ត ។ ភិក្ខុ ១ អង្គទៀត អាស្រ័យបញ្ញាជាទីពឹងផ្អែក គិតថាអាត្មាអញនឹងញ៉ាំងលោកុត្តរធម៌ឲ្យកើតដោយបញ្ញា, ហើយក៏ធ្វើបញ្ញាឲ្យជាធំ ឲ្យជាធុរៈ ឲ្យជាប្រធាន ក៏បានសម្រេចលោកុត្តរធម៌ ។

សេចក្តីនេះប្រៀបដូចអមច្ចបុត្រ ៤ នាក់ ត្រូវការចង់បានយសសក្តិដ៏ខ្ពង់ខ្ពស់រៀងខ្លួន ក៏ចូលទៅបម្រើខ្លួនដល់ព្រះ-

មហាក្សត្រ  អមច្ចបុត្រទី ១ អាស្រ័យឧបដ្ឋានៈការបំរើ ទំយក
ចិត្តទុកដាក់គាល់បំរើមិនប្រហែសធ្វេស  មិនឲ្យព្រះមហាក្សត្រ
ត្អូញព្រះទ័យ ត្រាតែព្រះមហាក្សត្រពេញព្រះទ័យរីករាយ ប្រោស
ប្រាណព្រះរាជទានយសសក្តិតាំងជាមន្ត្រីធំ ។ អមច្ចបុត្រទី ២
អាស្រ័យសូរភាវៈ សេចក្តីក្លាហាន ទំយកចិត្តទុកដាក់ផ្គាប់ព្រះ
មហាក្សត្រដោយសេចក្តីក្លាហានមិនខ្លាចស្លាប់ កាលបើមាន
វិបរិតបះបោមានចោរជាសត្រូវ កទ័ពនៅទីខែត្រណាស្រុកណា
ក្នុងដែនអាណាចក្រព្រះមហាក្សត្រ ក៏ទំយកចិត្តទុកដាក់ចេញ
ទៅបង្ក្រាបសត្រូវត្រាតែបាក់បបខ្លបខ្លាចអំណាចតេជៈ ស្ងប់
ស្ងាត់បាត់បលាបល ព្រះមហាក្សត្រទ្រង់ពេញព្រះទ័យទ្រង់ព្រះ
រាជទានយសសក្តិទ្រង់តាំងជាមន្ត្រីធំឡើង ។ អមច្ចបុត្រទី ៣
អាស្រ័យជាតិព្រោះខ្លួនជាអ្នកមានជាតិត្រកូលពូជអំបូរអ្នកស្តុក
ស្តម្ភ ក៏ចូលទៅផ្គាប់ព្រះមហាក្សត្រទំដុសខាត់គំនិតមារយាទ
ឲ្យត្រឹមត្រូវ ព្រះមហាក្សត្រទ្រង់យល់ថាបុរសនេះមានពូជត្រ-
កូលល្អមារយាទត្រឹមត្រូវ ទ្រង់ព្រះរាជទានយសសក្តិតាំងជា
មន្ត្រីធំឡើង ។ អមច្ចបុត្រទី ៤ អាស្រ័យមន្តគឺការចេះដឹងសិល្ប-

សាស្ត្រគ្រប់មុខ ក៏ចូលទៅផ្គាប់ព្រះរាជាយកមន្តនោះជាទីពឹងផ្អែក ព្រះរាជាទ្រង់ជ្រាបថាបុរសនេះមានបំណេះវិជ្ជាច្រើន ទ្រង់ប្រោសព្រះរាជទានយសសក្ដិតាំងជាមន្ត្រីធំឡើង ។ សេចក្ដីនេះប្រៀបដូចភិក្ខុ ៤ អង្គខាងដើម ភិក្ខុទី ១ បានសម្រេចលោកុត្តរធម៌ ដោយឆន្ទិទ្ធិបាទ ព្រោះធ្វើឆន្ទៈឲ្យជាធំ ឲ្យជាធុរៈ ឲ្យជាប្រធាន ដូចអមច្ចបុត្រទី ១ បានសម្រេចយសសក្ដិដោយឧបដ្ឋានៈការគាល់បំរើព្រះរាជា ។ ភិក្ខុទី ២ បានសម្រេចលោកុត្តរធម៌ ដោយវិរិយិទ្ធិបាទ ព្រោះធ្វើវិរិយៈឲ្យជាធំ ឲ្យជាធុរៈ ឲ្យជាប្រធាន ដូចជាអមច្ចបុត្រទី ២ បានសម្រេចយសសក្ដិដោយសូរភាវៈ សេចក្ដីក្លាហានអាចបង្ក្រាបសត្រូវបាន ។ ភិក្ខុទី ៣ បានសម្រេចលោកុត្តរធម៌ ដោយចិត្តិទ្ធិបាទ ព្រោះធ្វើចិត្តឲ្យជាធំ ឲ្យជាធុរៈ ឲ្យជាប្រធាន ដូចអមច្ចបុត្រទី ៣ បានសម្រេចយសសក្ដិ ដោយជាតិត្រកូលដ៏ខ្ពង់ខ្ពស់គំនិតមារយាទថ្លៃថ្លា ។ ភិក្ខុទី ៤ បានសម្រេចលោកុត្តរធម៌ ដោយវីមំសិទ្ធិបាទ ព្រោះធ្វើបញ្ញាឲ្យជាធំ ឲ្យជាធុរៈ ឲ្យជាប្រធាន ដូចអមច្ចបុត្រទី ៤ បានសម្រេចយសសក្ដិ ដោយមន្តគឺការចេះដឹងសិល្បសាស្ត្រគ្រប់មុខ ។

១ទៀតផង ឬទ្ធិបាទទាំង ៤ បើបុគ្គលឯណាបានបំរើនដោយប្រពៃហើយ បុគ្គលនោះវេលាដែលបានសម្រេចមហគ្គតធម៌ក្តី លោកុត្តរធម៌ក្តី និងមានឫទ្ធិអស្ចារ្យវិសេសផ្សេង ៗ មានហោះទៅឰដ៏អាកាសបានជាដើមដូចភិក្ខុ ៣០ អង្គ ។

មានរឿងថា គ្រាកាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មមាននៅឡើយ ព្រះអង្គគង់ក្នុងវត្តព្រះជេតពន ។ ថ្ងៃ ១ មានភិក្ខុ ៣០ អង្គចូលទៅគាល់ព្រះសាស្តា ។ ព្រះអានន្ទត្ថេរនិមន្តមកក្នុងវេលាធ្វើវត្តព្រះសាស្តា បានឃើញភិក្ខុទាំង ៣០ អង្គកំពុងគាល់ ក៏មិនហ៊ានចូល ទើបទ្រង់ឈរចាំឰដ៏ខ្លោងទ្វារ គិតថាចាំព្រះអង្គធ្វើបដិសណ្ឋារនឹងភិក្ខុទាំងនោះរួចស្រេចសិមចូលធ្វើវត្ត ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារនឹងភិក្ខុទាំងនោះ ទ្រង់សំដែងធម្មកថាជាទីរលឹកដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងអស់នោះ លុះបានស្តាប់ធម្មកថាហើយ ក៏បានសម្រេចព្រះអរហត្តគ្រប់ព្រះអង្គ ក៏នាំគ្នាហោះទៅដោយអាកាសអស់ទៅ ។ ព្រះអានន្ទបង្អង់ចាំយូរពេក ក៏ចូលទៅគាល់ព្រះសាស្តាក្រាបទូលសួរថាភិក្ខុទាំង ៣០ អង្គនិមន្តទៅណាបាត់អស់ហើយ ។ ព្រះអង្គមានព្រះបន្ទូល

ឋានគេទៅវិញអស់ហើយ ។ បុះគេទៅតាមផ្លូវណាទ្រង់ព្រះអង្គមិន
ឃើញ ។ គេទៅតាមអាកាស ។ ភិក្ខុទាំងនោះសុទ្ធតែជាព្រះ
ទីណាស្រេចឬអ្វី ។ អើអានន្ទ ភិក្ខុទាំងនោះបានស្តាប់ធម៌ក្នុង
សំណាក់តថាគត បានសម្រេចព្រះអរហត្តអស់ហើយ ។ ដ៏ប
ជួនក្នុងខណៈនោះមានសត្វហង្ស ១ ហ្វូងហើរមកតាមអាកាស
គេមើលឃើញច្រើនគ្នា ។ ព្រះអង្គមានព្រះបន្ទូលថាម្នាលអានន្ទ
ឥទ្ធិបាទទាំង៤ បើបុគ្គលឯណាបានចំរើនដោយប្រពៃហើយ
បុគ្គលនោះរមែងទៅតាមអាកាសបាន ដូចជាសត្វហង្សទាំង
នោះឯង ។

១ទៀតឥទ្ធិបាទទាំង ៤ បើបុគ្គលឯណាបានចំរើនដោយ
ល្អហើយ បុគ្គលនោះមានអាយុយឿនយូរស្ថិតនៅបានតាម
កំណត់អាយុកប្បឬច្រើនជាងអាយុកប្បក៏មាន ។

មានសេចក្តីក្នុងមហាបរិនិព្វានសូត្រថា គ្រាកាលដែល
ព្រះអង្គជិតចូលបរិនិព្វាន ព្រះអង្គគង់ក្នុងបាភាលចេតិយ ព្រះ-
អង្គមានព្រះបន្ទូលនឹងព្រះអានន្ទថា ម្នាលអានន្ទឥទ្ធិបាទទាំង៤
បើបុគ្គលឯណានិមួយបានចំរើនដោយប្រពៃហើយ បុគ្គលនោះ

បើមានប្រាថ្នានឹងស្ថិតនៅ (រស់នៅ) ក៏គប្បីស្ថិតនៅបានគ្រប់កំណត់អាយុកប្ប[១] ឬច្រើនជាងអាយុកប្បទៅទៀតក៏បាន បំណែកអញតថាគត ក៏បានបំរើនឥទ្ធិបាទទាំង ៤ សព្វគ្រប់ហើយ បើតថាគតប្រាថ្នានឹងស្ថិតនៅ ក៏អាចនឹងស្ថិតនៅបានអស់កំណត់អាយុកប្ប ឬច្រើនជាងកំណត់អាយុកប្បទៅទៀតក៏បានដែរ ។ ព្រះអង្គមានព្រះបន្ទូលឱភាសរំភ្លឺព្រះអានន្ទដូច្នេះ ដើម្បីឲ្យព្រះអានន្ទក្រាបទូលអារាធនា សូមឲ្យព្រះអង្គគង់ស្ថិតនៅសិន កុំទាន់អាលចូលបរិនិព្វាន តែព្រះអានន្ទមិនអាចនឹងអារាធនាបានឡើយ ព្រោះមានមារចូលមកគ្របដណ្តប់បំភាន់គំនិតព្រះអានន្ទមិនឲ្យនឹកនាត្រង់ការអារាធនាបាន ព្រះអង្គមានព្រះបន្ទូលឱភាស ២ ដង ៣ ដង ក៏ព្រះអានន្ទមិនអារាធនា បានជាព្រះអង្គទ្រង់ចូលបរិនិព្វានទៅ ។

សំដែងមកនេះឲ្យឃើញថាព្រះពុទ្ធអង្គទ្រង់សរសើរឥទ្ធិបាទទាំង ៤ ថាជាធម៌មានអានុភាពធំ ជួយឲ្យបំរើនអាយុ ។

ចប់ឥទ្ធិបាទ

---

១— កំណត់អាយុរបស់មនុស្សដែលពេញគ្រប់គ្រាន់តាមកាលតាមសម័យដូចក្នុងសម័យព្រះពុទ្ធជាម្ចាស់យើងនេះ អាយុកប្បកំណត់ ១០០ឆ្នាំ ។

# ឥន្ទ្រិយ

ឥន្ទ្រិយ ប្រែថា ធម្មជាតជាធំ ឥន្ទ្រិយនេះមាន ៥ យ៉ាង គឺ សទ្ធិន្ទ្រិយៈ ឥន្ទ្រិយគឺសទ្ធា ១ វីរិយិន្ទ្រិយៈ ឥន្ទ្រិយគឺវីរិយៈ ១ សតិន្ទ្រិយៈ ឥន្ទ្រិយគឺសតិ ១ សមាធិន្ទ្រិយៈ ឥន្ទ្រិយគឺសមាធិ ១ បញ្ញិន្ទ្រិយៈ ឥន្ទ្រិយៈគឺបញ្ញា ១ ។

សទ្ធា សេចក្ដីជឿ មានជឿពោធិញ្ញាណរបស់ព្រះតថាគតជាដើមបានជាឈ្មោះថាឥន្ទ្រិយ ដោយអត្ថថាជាធំ ព្រោះគ្របសង្កត់នូវអស្សទ្ធិយៈ គឺសេចក្ដីមិនជឿបាន ។ វីរិយៈ សេចក្ដីឱហាតសង្វាតប្រឹងប្រែង បានជាឈ្មោះថាឥន្ទ្រិយ ដោយអត្ថថាជាធំ ព្រោះគ្របសង្កត់នូវកោសជ្ជៈ គឺសេចក្ដីខ្ជិលច្រអូសបាន។សតិ សេចក្ដីរលឹក មានរលឹកពុទ្ធគុណជាដើម បានជាឈ្មោះថាឥន្ទ្រិយ ដោយអត្ថថាជាធំ ព្រោះគ្របសង្កត់នូវបមាទៈ គឺសេចក្ដីប្រហែលធ្វេស បណ្ដោតបណ្ដោយបាន ។ សមាធិ ការដំកល់ចិត្តមាំ បានជាឈ្មោះថាឥន្ទ្រិយ ដោយអត្ថថាជាធំ ព្រោះគ្របសង្កត់នូវវិក្ខេបៈ គឺសេចក្ដីរាយមាយនៃចិត្តបាន ។ បញ្ញា សេចក្ដីដឹងច្បាស់ បានជាឈ្មោះថាឥន្ទ្រិយ ដោយអត្ថថាជាធំ ព្រោះគ្របសង្កត់នូវសម្មោហៈ គឺសេចក្ដីវង្វេងខ្លាំងបាន

១ ទៀត ព្រះអដ្ឋកថាចារ្យលោកបានបទវិគ្គហទុកក្នុងគម្ពីរសម្មោហវិនោទនីអដ្ឋកថាវិភង្គថា អធិមោក្ខលក្ខណេ ឥន្ទដ្ឋំ ការេតីតិ សទ្ធិន្ទ្រិយំ ធម្មជាតឯណា ញុំាងសហជាតធម៌ឲ្យធ្វើនូវសេចក្តីជាធំក្នុងការជឿជាលក្ខណ ព្រោះហេតុនោះធម្មជាតនោះឈ្មោះថា សទ្ធិន្ទ្រិយ ។ បគ្គហលក្ខណេ ឥន្ទដ្ឋំ ការេតីតិ វីរិយិន្ទ្រិយំ ធម្មជាតឯណា ញុំាងសហជាតធម៌ឲ្យធ្វើនូវសេចក្តីជាធំក្នុងការផ្គងឡើងជាលក្ខណ ព្រោះហេតុនោះធម្មជាតនោះឈ្មោះថាវីរិយិន្ទ្រិយ ។ ឧបដ្ឋានលក្ខណេ ឥន្ទដ្ឋំ ការេតីតិ សតិន្ទ្រិយំ ធម្មជាតឯណា ញុំាងសហជាតធម៌ឲ្យធ្វើនូវសេចក្តីជាធំ ក្នុងការប្រុងប្រយ័ត្នជាលក្ខណ ព្រោះហេតុនោះ ធម្មជាតនោះឈ្មោះថាសតិន្ទ្រិយ ។ អវិក្ខេបលក្ខណេ ឥន្ទដ្ឋំ ការេតីតិ សមាធិន្ទ្រិយំ ធម្មជាតឯណា ញុំាងសហជាតធម៌ឲ្យធ្វើនូវសេចក្តីជាធំ ក្នុងសេចក្តីមិនរាយមាយនៃចិត្តជាលក្ខណ ព្រោះហេតុនោះ ធម្មជាតនោះឈ្មោះថា សមាធិន្ទ្រិយ ។ ទស្សនលក្ខណេ ឥន្ទដ្ឋំ ការេតីតិ បញ្ញិន្ទ្រិយំ ធម្មជាតឯណា ញុំាងសហជាតធម៌ឲ្យធ្វើនូវសេចក្តីជាធំ ក្នុងការ

ឃើញឬយល់ជាលក្ខណៈ ព្រោះហេតុនោះ ធម្មជាតនោះឈ្មោះថាបញ្ញិន្ទ្រិយ ។

-ចប់ឥន្ទ្រិយ ។

ពលៈ

ពលៈ ប្រែថាកំឡាំង ឬថារឹងប៉ឹងមិនញាប់ញ័រដោយធម៌ជាសត្រូវ ឬជាទំនាស់ ពលៈនេះមាន៥យ៉ាងគឺ សទ្ធាពលៈ កំឡាំងគឺសទ្ធា ១ វីរិយពលៈ កំឡាំងគឺវីរិយៈ ១ សតិពលៈ កំឡាំងគឺសតិ ១ សមាធិពលៈ កំឡាំងគឺសមាធិ ១ បញ្ញាពលៈ កំឡាំងគឺបញ្ញា ១ ។

សទ្ធា សេចក្ដីជ្រះថ្លា ឬជឿ បានជាឈ្មោះថាពលៈដោយអត្ថថាមិនញាប់ញ័រ ព្រោះអស្សទ្ធិយៈ = សេចក្ដីមិនជឿមិនអាចគ្របសង្កត់បានឡើយ ។ វីរិយៈ សេចក្ដីព្យាយាមបានជាឈ្មោះថា ពលៈ ដោយអត្ថថាមិនញាប់ញ័រ ព្រោះកោសជ្ជៈ=សេចក្ដីខ្ជិលច្រអូសមិនអាចគ្របសង្កត់បានឡើយ ។ សតិ សេចក្ដីរលឹក បានជាឈ្មោះថាពលៈ ដោយអត្ថថាមិនញាប់ញ័រ ព្រោះបមាទៈ = សេចក្ដីប្រហែសធ្វេសមិនអាច

គ្របសង្កត់បានឡើយ ។ សមាធិ ការដំកល់ចិត្តមាំ បានជាឈ្មោះថា ពលៈ ដោយអត្ថថាមិនញាប់ញ័រ ព្រោះវិក្ខេបៈ= សេចក្ដីរាយមាយនៃចិត្ត មិនអាចគ្របសង្កត់បានឡើយ ។ បញ្ញា សេចក្ដីដឹងច្បាស់ បានជាឈ្មោះថា ពលៈ ដោយអត្ថថាមិនញាប់ញ័រ ព្រោះសម្មោហៈ = សេចក្ដីវង្វេងខ្លាំង មិនអាចគ្របសង្កត់បានឡើយ ។

វេលានេះខ្ញុំនឹងទាញយកពលសូត្រមកសំដែងឲ្យឃើញសេចក្ដីច្បាស់ក្នុងពលៈទាំង ៥ នោះតាមពុទ្ធាធិប្បាយ ។

៣៤ សូត្រ

បញ្ចិមានិ ភិក្ខវេ ពលានិ ម្នាលភិក្ខុទាំងឡាយ កំឡាំងនេះមាន ៥ ប្រការ ។ កតមានិ បញ្ច កំឡាំង ៥ ប្រការនោះតើដូចម្ដេច ។ សទ្ធាពលំ វិរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ កំឡាំងគឺសទ្ធា ១ កំឡាំងគឺវិរិយៈ ១ កំឡាំងគឺសតិ ១ កំឡាំងគឺសមាធិ ១ កំឡាំងគឺបញ្ញា ១ ។ កតមញ្ច ភិក្ខវេ សទ្ធាពលំ ម្នាលភិក្ខុទាំងឡាយ កំឡាំងគឺសទ្ធា

តើដូចម្តេច ។ ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហាតិ តថាគតស្ស ពោធិំ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ម្នាលភិក្ខុទាំងឡាយ ព្រះអរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿនោការត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គឆ្ងាយបាកកិលេសហើយ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ដោយខ្លួនឯង ដោយត្រូវពិតឥតមានខុស ព្រះអង្គបរិបូណ៌ដោយវិជ្ជានឹងចរណៈ ព្រះអង្គពោលនូវពាក្យពិរោះ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយគុណមានសីលជាដើម ព្រះអង្គជានាយសារថីទូន្មាននូវបុរសដែលគួរទូន្មាន ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំង ៤ ហើយញាំងអ្នកដទៃឲ្យត្រាស់ដឹងផង ព្រះអង្គមានគុណធម៌ដែលអ្នកប្រាជ្ញគប្បីសេពដោយហេតុនេះមួយៗ ។ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធាពលំ ម្នាលភិក្ខុទាំងឡាយ នេះហៅថាកំឡាំងគឺសទ្ធា ។ កតមញ្ច ភិក្ខវេ

វីរិយពលំ ម្នាលភិក្ខុទាំងឡាយ កំឡាំងគឺវីរិយៈតើដូចម្តេច ។ ឥធ ភិក្ខវេ អរិយសាវកោ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ម្នាលភិក្ខុទាំងឡាយ ព្រះអរិយសាវក ក្នុងសាសនានេះ បានប្រារព្ធព្យាយាមហើយ ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីបំប៉ននូវកុសលធម៌ទាំងឡាយឲ្យជាត់ធំបំរុងបំរើនប្រើនឡើង ជាអ្នកមានកំឡាំង មានសេចក្តីសង្វាតម៉ាំមួន មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ។ ឥទំ វុច្ចតិ ភិក្ខវេ វីរិយពលំ ម្នាលភិក្ខុទាំងឡាយនេះហៅថាកំឡាំងគឺវីរិយៈ ។ កតមញ្ច ភិក្ខវេ សតិពលំ ម្នាលភិក្ខុទាំងឡាយ កំឡាំងគឺសតិតើដូចម្តេច ។ ឥធ ភិក្ខវេ អរិយសាវកោ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ម្នាលភិក្ខុទាំងឡាយ ព្រះអរិយសាវក ក្នុងសាសនានេះ មានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្តម នឹករលឹកនូវអំពើដែលគេធ្វើមកជាយូរហើយក៏បាន ឬពាក្យសំដីដែល

គេនិយាយមកជាយូរហើយក៏បាន ។ ឥទំ វុច្ចតិ ភិក្ខវេ សតិ-
ពលំ ម្នាលភិក្ខុទាំងឡាយ នេះហៅថាកំឡាំងគឺសតិ ។ កត-
មញ្ច ភិក្ខវេ សមាធិពលំ ម្នាលភិក្ខុទាំងឡាយ កំឡាំងគឺ
សមាធិតើដូចម្តេច ។ ឥធ ភិក្ខវេ អរិយសាវកោ វិវិច្ចេវ កាមេហិ
វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជម្បីតិសុខំ
បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ម្នាលភិក្ខុទាំងឡាយ ព្រះអ-
រិយសាវកក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់
ចាកអកុសលធម៌ទាំងឡាយគឺនីវរណទាំង ៥ បានដល់នូវបឋ
មជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិនិងសុខ
កើតអំពីសេចក្តីស្ងាត់នោះ ១ ។ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ
សម្បសាទនំ ចេតសោឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិ-
ជម្បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ បានរម្ងាប់
វិតក្កវិចារអស់ហើយ បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើត
មានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មាន
សភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ
និងសុខកើតអំពីសមាធិគឺបឋមជ្ឈាន ១ ។ បីតិយា ច វិរាគា

ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហា-រីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ តៀយណាយបាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតី ដឹងខ្លួនដោយល្អផង បានសោយនូវសុខដោយនាមកាយផង ព្រះអរិយទាំងឡាយតែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈានរនោះថា បុគ្គលដែលបានតតិយជ្ឈាន រមែងប្រកបដោយឧបេក្ខា មានស្មារតីល្អ មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះហេតុតែតតិយជ្ឈានឯណា ក៏បានដល់នូវតតិយជ្ឈាននោះ ១ ។ សុខស្ស ចបហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធិំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ បានលះបង់នូវសុខនឹងទុក្ខអស់ហើយ មានសោមនស្សនឹងទោមនស្សអស់ហើយ ក្នុងកាលមុន បានដល់នូវចតុត្ថជ្ឈាន មិនមានទុក្ខមិនមានសុខ (ឧបេក្ខា) មានសតិដ៏បរិសុទ្ធិដោយឧបេក្ខា ១ ។ ឥទំ វុច្ចតិ ភិក្ខវេ សមា-ធិពលំ ម្នាលភិក្ខុទាំងឡាយនេះហៅថា កំឡាំងគឺសមាធិ ។

កតមញ្ច ភិក្ខវេ បញ្ញាពលំ ម្នាលភិក្ខុទាំងឡាយ កំឡាំងគឺបញ្ញា តើដូចម្តេច ។ ឥធ ភិក្ខវេ អរិយសាវកោ បញ្ញវា ហោតិ ឧទយត្ថ-គាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មា-ទុក្ខក្ខយគាមិនិយា ម្នាលភិក្ខុទាំងឡាយ ព្រះអរិយសាវក ក្នុងសាសនានេះ ជាអ្នកមានបញ្ញា ប្រកបដោយបញ្ញាអាចកំណត់នូវសេចក្តីកើតនឹងរលត់បាន ជាបញ្ញាដ៏ប្រសើរ ជាបញ្ញាអាចទំលុះទំលាយនូវគំនរនៃលោភជាដើម ជាបញ្ញាជាគ្រឿងដល់នូវសេចក្តីអស់ទៅនៃទុក្ខដោយប្រពៃ ។ ឥទំ វុច្ចតិ ភិក្ខវេ បញ្ញាពលំ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កំឡាំងគឺបញ្ញា ។

ចប់ពលសូត្រ ។

ពលៈទាំង៥ បណ្ឌិតគប្បីចូលចិត្តតាមពលសូត្រនេះចុះ

សូម្បីតែឥន្ទ្រិយ ៥ ខាងដើមក៏ត្រូវចូលចិត្តសេចក្តីតាមពលសូត្រនេះដែរ

ចប់ពលៈ ។

## ពោជ្ឈង្គ

ពោជ្ឈង្គនេះបាននិយាយខ្លះហើយក្នុងធម្មានុបស្សនាសតិ-បដ្ឋានខាងដើម តែបើទុកជានិយាយហើយក៏ត្រូវតែនិយាយទៀតខានមិនបាន ដើម្បីដំរូវតាមបទមាតិកាធម៌ដែលរៀបរៀងទុកខាងដើមឲ្យត្រូវតាមលំដាប់គ្នា ។

ពោជ្ឈង្គៈ ប្រែថាធម៌ជាអង្គគឺជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ឬថាជាហេតុនៃការត្រាស់ដឹងនូវចតុរារិយសច្ច ពោជ្ឈង្គនេះមាន៧យ៉ាងគឺ សតិសម្ពោជ្ឈង្គ សតិជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច១ ធម្មវិចយសម្ពោជ្ឈង្គ បញ្ញាជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច១ វិរិយសម្ពោជ្ឈង្គ វិរិយៈជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច១ បីតិសម្ពោជ្ឈង្គ បីតិសេចក្តីឆ្អែតកាយឆ្អែតចិត្ត ជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច១ បស្សទ្ធិសម្ពោជ្ឈង្គ បស្សទ្ធិសេចក្តីរម្ងាប់កាយរម្ងាប់ចិត្តជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច១ សមាធិសម្ពោជ្ឈង្គ សមាធិជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច១ ឧបេក្ខាសម្ពោជ្ឈង្គ ឧបេក្ខាជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច១ ។

មានសេចក្តីតាមពុទ្ធាធិប្បាយក្នុងពោជ្ឈង្គវិភង្គព្រះអភិធម្មថាឥធ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា អយំ វុច្ចតិ

សតិសម្ពោជ្ឈង្គោ ភិក្ខុក្នុងសាសនានេះ មានស្មារតី ប្រកប ដោយស្មារតីនិងបញ្ញាដ៏ឧត្តម នឹករលឹកនូវអំពើដែលគេធ្វើមក ជាយូរ(១)ហើយក៏បាន ឬពាក្យសំដីដែលគេនិយាយមកជាយូរ(២) ហើយក៏បាន នេះហៅថាសតិសម្ពោជ្ឈង្គ(៣) ។ សោ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បរិវីមំសំ អាបជ្ជតិ អយំ វុច្ចតិ ធម្មវិចយសម្ពោជ្ឈង្គោ ភិក្ខុនោះកាលបើមានស្មារតីដូច្នោះ រមែងពិចារណា(៤) ត្រិះត្រិះ(៥) ដល់នូវការក្រឡេកមើល ឬស្វែងរក នូវធម៌នោះ(៦) នេះហៅថា ធម្មវិចយសម្ពោជ្ឈង្គ(៧) ។ តស្ស តំ ធម្មំ បញ្ញាយ វិចិនតោ បវិចិនតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ អយំ វុច្ចតិ វីរិយសម្ពោជ្ឈង្គោ កាលដែល ភិក្ខុនោះ ពិចារណាត្រិះត្រិះ ដល់នូវការក្រឡេកមើល ឬស្វែងរក នូវធម៌នោះ ដោយបញ្ញា សេចក្ដីព្យាយាមមិនធូរថយ ភិក្ខុ

---

១– វត្ថុក្ដី កសិណមណ្ឌលក្ដី កសិណបរិកម្មក្ដី ដែលខ្លួនឬអ្នកដទៃធ្វើដោយកាយជាយូរអង្វែងហើយ ។ ២– ធម្មកថា ដែលខ្លួនឬអ្នកដទៃសំដែងដោយវាចាជាយូរអង្វែងហើយ ។ ៣– សតិប្រកបដោយវិបស្សនា អាចញុំាងពោជ្ឈង្គ ដ៏សេសឲ្យកើតឡើង ហៅថា សតិសម្ពោជ្ឈង្គ ។ អដ្ឋកថា ។ ៤– ៥– ពិចារណាឃើញថា អនិច្ចំ ទុក្ខំ អនត្តា ។ ៦– សំដៅយកអំពើដែលគេធ្វើមកជាយូរហើយ និងពាក្យសំដីដែលគេនិយាយមកជាយូរហើយ។ ៧– វិបស្សនាញាណអាចញុំាងពោជ្ឈង្គ ឲ្យកើតឡើងហៅថាធម្មវិចយសម្ពោជ្ឈង្គ ។

នោះបានប្រារព្ធហើយ នេះហៅថាវីរិយ[1]សម្ពោជ្ឈង្គ ។ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា អយំ វុច្ចតិ បីតិសម្ពោជ្ឈង្គោ បីតិដែលប្រាសចាកអាមិស[2] ៣ យ៉ាង រមែងកើតឡើង ដល់ភិក្ខុដែលបានប្រារព្ធព្យាយាមហើយ នេះហៅថាបីតិ[3]សម្ពោជ្ឈង្គ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តំបិ បស្សម្ភតិ អយំ វុច្ចតិ បស្សទ្ធិសម្ពោជ្ឈង្គោ ភិក្ខុដែលមានចិត្ត ប្រកបដោយបីតិ កាយ[4]ក៏ស្ងប់រម្ងាប់[5] ចិត្ត[6]ក៏ស្ងប់រម្ងាប់ នេះហៅថាបស្សទ្ធិ[7]សម្ពោជ្ឈង្គ ។ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ អយំ វុច្ចតិ សមាធិសម្ពោជ្ឈង្គោ ភិក្ខុដែលមាននាមកាយស្ងប់រម្ងាប់ហើយ មានសេចក្ដីសុខ ចិត្តរមែងតាំងនៅមាំ នេះហៅថាសមាធិ[8]សម្ពោជ្ឈង្គ ។ សោ តថាសមាហិតំ ចិត្តំ សាធុកំ

---

១– វីរិយៈ ប្រកបដោយវិបស្សនាអាចញុំាងពោជ្ឈង្គ ឲ្យកើតឡើងហៅថា វីរិយសម្ពោជ្ឈង្គ ។ ២– អាមិស ៣ យ៉ាងគឺ កាម ១ លោក ១ វដ្ដ ១ ។ ៣– បីតិប្រកបដោយវិបស្សនា អាចញុំាងពោជ្ឈង្គឲ្យកើតឡើង ហៅថាបីតិសម្ពោជ្ឈង្គ ។ ៤– កាយៈសំដៅយកនាមកាយគឺ អរូបខន្ធ ៣ បានខាងវេទនាខន្ធ១ សញ្ញាខន្ធ១ សង្ខារខន្ធ១ ។ ៥– គ្មានសេចក្ដីក្រវល់ក្រវាយដោយកិលេស ។ ៦– វិញ្ញាណខន្ធ ។ ៧– បស្សទ្ធិ ប្រកបដោយវិបស្សនា អាចញុំាងពោជ្ឈង្គឲ្យកើតឡើងហៅថាបស្សទ្ធិសម្ពោជ្ឈង្គ ។ អដ្ឋកថា ។ ៨– ចិត្តេកគ្គតា ប្រកបដោយវិបស្សនា អាចញុំាងពោជ្ឈង្គឲ្យកើតឡើង ហៅថា សមាធិសម្ពោជ្ឈង្គ ។

អជ្ឈុបេក្ខិតា ហោតិ អយំ វុច្ចតិ ឧបេក្ខាសម្ពោជ្ឈង្គោ ភិក្ខុនោះ សំឡឹងមើល[១]ដោយប្រពៃ បំពោះចិត្តដែលតាំងនៅមាំហើយដោយបការដូច្នោះ នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ[២] ។

១ទៀតពោជ្ឈង្គទាំង៧នេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងចំពោះព្រះមហាកស្សបថា សត្តិមេ កស្សប ពោជ្ឈង្គា មយា សម្មទក្ខាតា ភាវិតា ពហុលីកតា អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ម្នាលកស្សប ពោជ្ឈង្គទាំង៧នេះ ដែលតថាគតបានសំដែងហើយដោយប្រពៃ បើបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់នូវអភិញ្ញេយ្យធម៌ ដើម្បីត្រាស់ដឹងគឺមគ្គ ដើម្បីព្រះនិព្វាន ។

ចប់ពោជ្ឈង្គ ។

## អដ្ឋមគ្គ

មគ្គៈ ប្រែថា សភាវដែលបុគ្គលអ្នកត្រូវការដោយព្រះនិព្វានតែងស្វែងរក ឬថា សភាវស្វែងរកនូវព្រះនិព្វាន ឬថា សភាវសំឡាប់នូវកិលេសប្រព្រឹត្តទៅ ដោយបទវិគ្គហថា និព្វានត្ថិ-

---

១– គ្មានសេចក្ដីខ្វល់ខ្វាយក្នុងការលះបង់នឹងការចំរើននូវធម៌ទាំងនោះ ។ ២– អាការជាកណ្ដាល មិនបន្ថយមិនបង្កើននូវពោជ្ឈង្គទាំង ៦ ខាងដើម ហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ។

កេហិ មគ្គិយតិ និព្វានំ វា មគ្គតិ កិលេសេ វា មារេន្តោ គច្ឆតីតិ មគ្គោ ។ ក៏ឯមគ្គនោះមានអង្គ ៨ គឺ សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ ១ សម្មាសង្កប្ប សេចក្តីត្រិះរិះត្រូវ ១ សម្មាវាចា និយាយត្រូវ ១ សម្មាកម្មន្ត ការងារត្រូវ ១ សម្មាអាជីវ ការចិញ្ចឹមជីវិតត្រូវ ១ សម្មាវាយាម ព្យាយាមត្រូវ ១ សម្មាសតិ សេចក្តីរលឹកត្រូវ ១ សម្មាសមាធិ ការដំកល់ចិត្តត្រូវ ១ ។ អង្គមគ្គនេះមានពុទ្ធាធិប្បាយក្នុងគម្ពីរព្រះសូត្រមានច្រើនកន្លែង តែក្នុងទីនេះខ្ញុំនាំយកពុទ្ធាធិប្បាយក្នុងមគ្គវិភង្គព្រះអភិធម្ម មកសំដែងដើម្បីញុំាងសាធុជនឲ្យជ្រាបសេចក្តីក្នុងអង្គមគ្គនោះៗ ។

តត្ថ កតមា សមាទិដ្ឋិ ទុក្ខេ ញាណំ ទុក្ខសមុទយេ-ញាណាំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិ-បទាយ ញាណំ អយំ វុច្ចតិ សម្មាទិដ្ឋិ បណ្តាអង្គមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច សេចក្តីដឹងក្នុងកងទុក្ខ ១ សេចក្តីដឹងក្នុងតណ្ហាជាហេតុឲ្យកើតកងទុក្ខ ១ សេចក្តីដឹងក្នុងព្រះនិព្វានជាគ្រឿងរលត់នៃកងទុក្ខ ១ សេចក្តីដឹងក្នុងធម៌ប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វានជាគ្រឿងរលត់នៃកងទុក្ខ ១ នេះហៅថាសម្មាទិដ្ឋិ ។

តត្ថ កតមោ សម្មាសង្កប្បោ នេក្ខម្មសង្កប្បោ អព្យាបាទ-

សង្កប្បោ អវិហឹសាសង្កប្បោ អយំ វុច្ចតិ សម្មាសង្កប្បោ បណ្ដាអង្គមគ្គទាំងនោះ សម្មាសង្កប្បតើដូចម្ដេច សេចក្ដីត្រិះរិះក្នុងការចេញចាកកាម (ផ្នួស)១ សេចក្ដីត្រិះរិះក្នុងការមិនព្យាបាទ១ សេចក្ដីត្រិះរិះក្នុងការមិនបៀតបៀន១ នេះហៅថាសម្មាសង្កប្ប។

តត្ថ កតមា សម្មាវាចា មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អយំ វុច្ចតិ សម្មាវាចា បណ្ដាអង្គមគ្គទាំងនោះ សម្មាវាចាតើដូចម្ដេច ការវៀរចាកនិយាយពាក្យកុហក ១ ការវៀរចាកវាចាស៊កសៀតញុះញង់ឲ្យគេបែកគ្នា ១ ការវៀរចាកវាចាត្រគោះអាក្រក់ ១ ការវៀរចាកនិយាយពាក្យរោយរាយឥតប្រយោជន៍១ នេះហៅថាសម្មាវាចា ។

តត្ថ កតមោ សម្មាកម្មន្តោ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី អយំ វុច្ចតិ សម្មាកម្មន្តោ បណ្ដាអង្គមគ្គទាំងនោះ សម្មាកម្មន្តតើដូចម្ដេច ការវៀរចាកបាណាតិបាត (សំឡាប់សត្វ)១ ការវៀរចាកអទិន្នាទាន (លួចទ្រព្យគេ)១ ការវៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ១ នេះហៅថា សម្មាកម្មន្ត ។

តត្ថ កតមោ សម្មាអាជីវោ ឥធ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិតំ កប្បេតិ អយំ វុច្ចតិ សម្មាអាជីវោ បណ្ដាអង្គមគ្គទាំងនោះ សម្មាអាជីវតើដូចម្ដេច ។ ព្រះអរិយសាវក ក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស ហើយសំរេចជីវិតដោយការចិញ្ចឹមជីវិតត្រូវ នេះហៅថាសម្មាអាជីវ ។

តត្ថ កតមោ សម្មាវាយាមោ ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អយំ វុច្ចតិ សម្មាវាយាមោ បណ្ដាអង្គមគ្គទាំងនោះ សម្មាវាយាមតើដូចម្ដេច ភិក្ខុក្នុងសាសនានេះ

ញ៉ាំងឆន្ទៈឲ្យកើតមានឡើង ព្យាយាមប្រារព្ធសេចក្ដីព្យាយាម ផ្គងចិត្ត ដំកល់ចិត្តឡើង ដើម្បីរារាំង អកុសលធម៌ដ៏លាមក ដែលមិនទាន់កើតមានឡើង កុំឲ្យកើតឡើង១ ញ៉ាំងឆន្ទៈឲ្យកើតមានឡើង ព្យាយាមប្រារព្ធសេចក្ដីព្យាយាម ផ្គងចិត្ត ដំកល់ចិត្តឡើង ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមក ដែលកើតមានរួចហើយ១ ញ៉ាំងឆន្ទៈឲ្យកើតមានឡើង ព្យាយាមប្រារព្ធសេចក្ដីព្យាយាម ផ្គងចិត្ត ដំកល់ចិត្តឡើង ដើម្បីបណ្ដុះបណ្ដាលកុសលធម៌ ដែលមិនទាន់កើតមានឡើង ឲ្យកើតមានឡើង១ ញ៉ាំងឆន្ទៈឲ្យកើតមានឡើង ព្យាយាមប្រារព្ធសេចក្ដីព្យាយាម ផ្គងចិត្ត ដំកល់ចិត្តឡើង ដើម្បីកពូនកុសលធម៌ ដែលកើតមានឡើងហើយ ឲ្យស្ថិតថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែចំរើនឡើងទៀត ឲ្យធំទូលាយឡើង ឲ្យកើតឡើងឲ្យពោរពេញឡើង១ នេះហៅថាសម្មាវាយាម ។

តត្ថ កតមា សម្មាសតិ ឥធ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបិ. សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី

សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អយំ វុច្ចតិ សម្មាសតិ បណ្ដាអង្គមគ្គទាំងនោះ សម្មាសតិតើដូចម្ដេច ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ មានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួនដោយល្អ មានស្មារតី កំចាត់បង់នូវអភិជ្ឈានឹងទោមនស្ស ក្នុងលោកគឺកាយឬឧបាទានក្ខន្ធ១ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួនដោយល្អ មានស្មារតី កំចាត់បង់នូវអភិជ្ឈានឹងទោមនស្សក្នុងលោក១ ពិចារណានូវចិត្តក្នុងចិត្ត មានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួនដោយល្អ មានស្មារតី កំចាត់បង់នូវអភិជ្ឈានឹងទោមនស្សក្នុងលោក១ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួនដោយល្អ មានស្មារតី កំចាត់បង់នូវអភិជ្ឈានឹងទោមនស្ស ក្នុងលោក១ នេះហៅថាសម្មាសតិ។

តត្ថ កតមោ សម្មាសមាធិ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធិំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ សម្មាសមាធិ បណ្ដាអង្គមគ្គទាំងនោះ សម្មាសមាធិតើដូចម្ដេច ភិក្ខុក្នុងសាសនានេះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយគឺនីវរណទាំង ៥ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិនិងសុខកើតអំពីសេចក្ដីស្ងាត់នោះ ១ ។

បានរម្ងាប់វិតក្កនឹងវិចារអស់ហើយ បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានខ្លួន មានសេចក្តីជ្រះថ្លាដ៏ឧត្តមគឺសទ្ធាមានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិនឹងសុខកើតអំពីសមាធិគឺបរិមជ្ឈាន១ ។

មានចិត្តនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយល្អផង សោយនូវសុខដោយនាមកាយផង ព្រះអរិយទាំងឡាយតែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈាននោះថា បុគ្គលដែលបានតតិយជ្ឈានរមែងប្រកបដោយឧបេក្ខា មានស្មារតីល្អ មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះហេតុនៃតតិយជ្ឈានឯណា ក៏បានដល់នូវតតិយជ្ឈាននោះ១ ។

បានលះបង់នូវសុខនឹងទុក្ខអស់ហើយ មានសោមនស្សនឹងទោមនស្សអស់ហើយក្នុងកាលមុន ក៏បានដល់នូវចតុត្ថជ្ឈាន មានវេទនាមិនមែនជាទុក្ខមិនមែនជាសុខគឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា១ នេះហៅថាសម្មាសមាធិ ។

ចប់អដ្ឋមគ្គ ។

បោះពុម្ពតាមច្បាប់ដើម

លើកទី ១

នៅវត្ត បាលិលេយ្យ ចំនួន ១០០ ច្បាប់


**PALELAI BUDDHIST TEMPLE, INC.**
240 Greenwich Street
Philadelphia, PA 19147
Tel: (215) 339-5830-40